# ឯកសារគោលគំនិតសម្រាប់គំរោងមិនមែនឥណទាន

ឧបសម្ព័ន្ធនេះរួមមានឯកសារទស្សនាទានសម្រាប់គំរោងមិនមែនឥណទានដែលត្រូវបានគ្រោងទុកៈ

(i) តារាង ក៥.១: គម្រោងធ្វើឱ្យមានស្ថេរភាពទីជំរាលបឹងទន្លេសាប

(ii) តារាង ក៥.២: គម្រោងអភិវឌ្ឍន៍និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

(iii) តារាង ក៥.៣: ការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាបទី ៣

(iv) តារាង ក៥.៤: ការសិក្សាអំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធសំណង់លើនេសាទនៃបឹងទន្លេសាប

(v) តារាង ក៥.៥: ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាបទី ២

(vi) តារាង ក៥.៦: ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុទី ១ (កម្មវិធីវងទី៣)

(vii) តារាង ក៥.៧: អគារសម្រាប់ក្រុមប្រឹក្សាឃុំ - តំណាក់កាលទី ២

(viii) តារាង ក៥.៨: មជ្ឈមណ្ឌលសមាហរណកម្មផ្តល់អំណាចដល់ស្ត្រី

(ix) តារាង ក៥.៩: អន្តេវាសិកដ្ឋានសម្រាប់សិស្សនារីនៅសាលាមធ្យមសិក្សា

(x) តារាង ក៥.១០: ការស្តារនីតិសម្បទាអយស្ម័យយានកម្ពុជា

(xi) តារាង ក៥.១១: កិច្ចអភិវឌ្ឍន៍ទេសចរណ៍ GMS ដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រ

(xii) តារាង ក៥.១២: គំនិតផ្តួចផ្តើមអាជីវកម្មកម្ពុជានៅក្នុងកិច្ចអភិវឌ្ឍន៍ជនបទ

## តារាង ក៥.១៖ គម្រោងធ្វើឱ្យមានស្ថេរភាពតំបន់ទំនាបបឹងទន្លេសាប

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ៖** ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

☐ ប្រភេទកម្ចីឥណទាន

- ☐ ឥណទានគម្រោង
- ☐ ឥណទានកម្មវិធីកំណែទម្រង់
- ☐ ឥណទានវិស័យ
- ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
- ☐ ផ្សេងទៀត៖

☒ ប្រភេទមិនមែនជាកម្ចីឥណទាន

- ☒ សំរាប់ត្រៀមរៀបចំគម្រោង
- ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
  - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
  - ☐ ផ្សេងទៀត៖

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ៖ កសិកម្ម និង ធនធានធម្មជាតិ

អនុវិស័យ៖ កិច្ចអភិវឌ្ឍន៍ជនបទ

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន
☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: ការជម្រុញកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កិច្ចអភិវឌ្ឍន៍តំបន់ជនបទ អភិរក្សធនធានធម្មជាតិ

**៣. វិសាលភាពគ្របដណ្តប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** I. Fox ប្រធានអ្នកឯកទេសគម្រោង (ធនធានធម្មជាតិ)

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** មុខព្រួញនៃយុទ្ធសាស្ត្របឹងទន្លេសាបរបស់ ADB គឺការគ្រប់គ្រងធនធានធម្មជាតិ កិច្ចអភិវឌ្ឍន៍ស្ថាប័ន និងការកសាងសមត្ថភាព និងការកាត់បន្ថយភាពក្រីក្រ និងការជម្រុញជីវភាពប្រកបដោយស្ថេរភាព។ យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេសរបស់ ADB ឆ្នាំ ២០០៤-២០០៦ ឆ្លុះបញ្ចាំងនូវវិធីសាស្ត្រអនុវត្តន៍លើវិស័យចំរុះរបស់ ADB សំរាប់អាងបឹងទន្លេសាបដែលមានផែនការអនុវត្តន៍ក្នុងរយៈពេល ១០ ឆ្នាំខាងមុខនេះ។ ជំនួយបច្ចេកទេស (TA) សំរាប់ត្រៀមរៀបចំគម្រោងនេះ នឹងបំពេញបន្ថែមលើកិច្ចប្រឹងប្រែងទាំងឡាយដែលកំពុងត្រូវបានធ្វើឡើង ដើម្បីរៀបចំសហគមន៍គ្រប់គ្រងធនធានធម្មជាតិ ក្រោមគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (ឆ្នាំ ២០០២)។ គម្រោងនេះ នឹងជួយសហគមន៍ទាំងឡាយដែលរស់នៅក្នុងតំបន់លិចទឹកតាមរដូវ និងដែលមិនត្រូវបានកំណត់ជាចំណុចគោលដៅរបស់គម្រោង ជីវភាពប្រកបដោយចីរភាពនៅបឹងទន្លេសាប (ឆ្នាំ ២០០៥)។ សហគមន៍ទាំងនេះ គឺជាសហគមន៍ក្រីក្រដែលរស់នៅអាស្រ័យលើការនេសាទ កសិកម្មពឹងទឹកភ្លៀងដែលទទួលទិន្នផលទាប និងការរកឈើសំរាប់អុសដុត និងផលិតផលព្រៃឈើបន្ទាប់បន្សំដទៃទៀតពីអន្តរតំបន់នៃតំបន់ជីវៈបម្រុងបឹងទន្លេសាប។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃជំនួយបច្ចេកទេស គឺការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះនៅក្នុងអាងបឹងទន្លេសាបប្រកបដោយចីរភាព។ គោលបំណងរបស់គម្រោង គឺការរៀបចំគម្រោងមួយដើម្បីគ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិនៅក្នុងនិងនៅជុំវិញតំបន់ជីវៈចម្រុះបម្រុងបឹងទន្លេសាប

ដោយអនុលោមតាមគោលការណ៍ជីវៈចម្រុះបម្រុង តាមរយៈសកម្មភាពអភិវឌ្ឍន៍ជនបទ ដែលមានលក្ខណៈវិមជ្ឈការ និងការចូលរួម។ គម្រោងនេះនឹង ជួយគាំទ្រដល់ការជំរុញសហគមន៍ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងការអនុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដើម្បីលើកកំពស់ចំណូលនៅជនបទ ដែលនាំអោយមានការជួយសម្រាលសំពាធលើធនធានធម្មជាតិនៃអាងបឹងទន្លេសាប។ គម្រោងនេះ ក៏នឹងធ្វើការស្រាវជ្រាវដើម្បីផ្តល់នូវជំរើសជាសកម្មភាពជីវភាពផ្សេងៗ និងការបង្កើនសមត្ថភាពសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ផ្អែកលើសហគមន៍។ គម្រោងនេះ នឹងប្រើប្រាស់នូវវិធីសាស្រ្តជាដំណាក់ៗ ដែលនឹងពង្រឹងភាពជាម្ចាស់ និងសមត្ថភាពរបស់សហគមន៍ តាមរយៈការធ្វើផែនការ ការអនុវត្តន៍ និងការតាមដាន និងការវាយតម្លៃ ដោយមានការចូលរួម។

គ. **សមាសភាគ និង សមិទ្ធិផល :** គម្រោងនេះ មានសមាសភាគចំនួនបីៈ (១) ការធ្វើចលនាសហគមន៍ និងការធ្វើផែនការជាយុទ្ធសាស្រ្ត (២) ការរៀបចំនិងការអនុវត្តន៍គំរោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដោយយកចិត្តទុកដាក់ជាពិសេសលើការថែរក្សាព្រៃឈើ និងប្រព័ន្ធធារាសាស្រ្តខ្នាតតូច និង (៣) ការផ្តល់នូវជម្រើសផ្សេងៗសំរាប់សកម្មភាពជីវភាព។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបានៈ** លទ្ធផលរំពឹងទុក និងសមិទ្ធិផលនៃគម្រោងនេះ នឹងរួមមាន (១) ការដាំព្រៃឈើឡើងវិញជាលក្ខណៈសហគមន៍នៅតំបន់ព្រៃឈើខូចខាតនៅក្នុងនិងនៅខាងលើតំបន់លិចទឹក (២) ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចសំរាប់សហគមន៍ ដូចជាផ្លូវលំជនបទ ស្ពានថ្មើជើង ប្រព័ន្ធបូមទឹកខ្នាតតូច និងអណ្តូង និងស្រះទឹកសហគមន៍ដើម្បីផ្គត់ផ្គង់ទឹកស្អាត (៣) ការកែលំអរនូវការផ្តល់សេវាកម្មនៅមូលដ្ឋានសម្រាប់ការចែកចាយទឹក ការគ្រប់គ្រងប្រព័ន្ធធារាសាស្រ្តក្នុងលក្ខណៈចូលរួម កសិកម្ម ការចិញ្ចឹមសត្វ ព្រៃឈើ និងដំណាំឈើ (៤) សេវាកម្មប្រើប្រាស់ឥណទាន (ការផ្សព្វផ្សាយពតិមានស្តីពីឥណទាន ការបណ្តុះបណ្តាលអំពីវិធីប្រើសេវាកម្មឥណទាន) (៥) ការបណ្តុះបណ្តាលជំនាញផ្សេងៗ ដើម្បីអាចមានជំរើសក្នុងការរកចំណូល និង (៦) ការធ្វើការស្រាវជ្រាវលើការមានទីផ្សារ និងព័តិមានអំពីតម្លៃ។

ស្ថាប័នប្រតិបត្តិ នឹងបញ្ចប់នូវសំណួរស្រាវជ្រាវរបស់ TA ដើម្បីវាយតំលៃលើការចំណាយសំរាប់ដំណើរការ TA និងលទ្ធផលសំរេចបាន ធ្វើការកត់សំគាល់លើបទពិសោធន៏កន្លងមក និងផ្តល់យោបល់សំរាប់ដំណើរការបន្ត។

ង. **បញ្ហា ឬការបារម្ភខាងសង្គមកិច្ច ឬបរិស្ថានៈ** ការប្រគល់ឡូត៍នេសាទនៅក្នុងបឹងទន្លេសាប ប្រមាណជា ៥០០.០០០ ហិកតា ក្នុងឆ្នាំ ២០០០ ទៅឱ្យសហគមន៍ដើម្បីគ្រប់គ្រងដោយខ្លួនឯង បាននាំឱ្យមានការធ្វើអាជីវកម្មក្នុងលក្ខណៈគ្មានការគ្រប់គ្រងដែលមិនដែលមានពីពេលមុន។ ជាលទ្ធផលវិបាកដែលកើតឡើងភ្លាមៗ គឺមានការដាក់សំពាធបន្ថែមទៅលើជង្រុកត្រីនានាដោយសហគមន៍ ដែលនៅជិតខាងនានាដែលកាលពីមុនពុំដែលមានប្រពៃណីនេសាទកន្លងមក។ សណ្តាប់ធ្នាប់ កំពុងត្រូវបានដាក់នៅក្នុងការគ្រប់គ្រងឡូត៍នេសាទ និងធនធានធម្មជាតិដទៃទៀតនៅក្នុងតំបន់លិចទឹក (ដោយមានជំនួយពីគម្រោងគ្រប់គ្រងបរិស្ថានទន្លេសាប និងគម្រោងជីវភាពប្រកបដោយចិរភាពនៅបឹងទន្លេសាប ដែល

ត្រូវបានស្នើឡើង) ។ ប៉ុន្តែ គេឃើញមានការបារម្ភ ដែលថាការកែលំអរផ្លូវលំ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត អាចសម្រួលដល់ការធ្វើអាជីវកម្មលើធនធានធម្មជាតិកាប់តែច្រើនឡើងថែមទៀត និងមានផលប៉ះពាល់ជាអវិជ្ជមានលើកិច្ចប្រឹងប្រែងដើម្បីគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និងការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ ជាពិសេសកំណើនប្រជាជន និងសំពាធអភិវឌ្ឍន៍។ កំណើននានានៃសកម្មភាពកសិកម្ម ជាពិសេស កសិកម្មផ្អែកលើធារាសាស្ត្រនៅក្នុងអន្តរតំបន់នៃតំបន់ជីវៈបម្រុងបឹងទន្លេសាប អាចនាំឱ្យមានការប្រើយ៉ាងច្រើនលើសលុប នូវសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (POPs) ដូចជា ថ្នាំសម្លាប់សត្វល្អិត និងគីមីកសិកម្មជាដើម។ គេក៏ឃើញមានផងដែរនូវហានិភ័យដែលថា ការកែលំអរផលិតភាពកសិកម្ម នៅក្នុងអន្តរតំបន់ អាចបង្កើតនូវហានិភ័យចំពោះការជំរុញអោយមានការកាប់ព្រៃឈើបន្ថែមទៀតដើម្បីអោយប្រែក្លាយទៅជាតំបន់កសិកម្ម។

ភាពក្រីក្រនៅក្នុងតំបន់កំណត់របស់គម្រោង គឺមានលក្ខណៈធ្ងន់ធ្ងរ ដោយមានប្រជាជនប្រហែល ៣៨% រស់នៅក្រោមបន្ទាត់ក្រីក្រតាមតួលេខផ្លូវការ។ ស្ត្រី មានប្រហែលជា ៥១% នៃចំនួនប្រជាជនដែលក្នុងនោះ គ្រួសារដែលមានស្ត្រីជាមេគ្រួសារមានប្រហែល ១៥-៣០%។ គ្រួសារដែលមានមេគ្រួសារជាស្ត្រី គឺស្ថិតនៅក្នុងចំណោមគ្រួសារដែលក្រីក្រ និងដែលឯកោបំផុត។ លើសពីនេះទៀត គេឃើញមាន ប្រជាជនផ្លាស់ទីលំនៅជនភៀសខ្លួនដែលធ្វើមាតុភូមិនិវត្តន៍ អន្តោរប្រវេសន៍ក្នុងស្រុក និងយោធាវិសាយក៏មានវត្តមាននៅក្នុងតំបន់ដែលនឹងត្រូវជួយដោយគម្រោង។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** NGOs នឹងត្រូវបានឱ្យចូលរួមធ្វើចលនាសហគមន៍ក្នុងអំឡុងពេលអនុវត្ត TA ត្រៀមរៀបចំគម្រោង ក៏ដូចជាក្នុងអំឡុងពេលអនុវត្តគម្រោងផងដែរ ហើយបណ្តាញរបស់ NGOs នឹងធានាឱ្យបាននូវការចែកចាយលទ្ធផលឱ្យបានទូលាយ។ សិក្ខាសាលាថ្នាក់ជាតិ នឹងត្រូវបានធ្វើឡើងដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍សំខាន់ៗ និងចំណុចធ្វើសេចក្តីសម្រេចចិត្តទាំងឡាយ។ ADB ក៏បោះផ្សាយផងដែរ នូវព្រឹត្តិប័ត្រប្រចាំឆមាសអំពីយុទ្ធសាស្ត្របឹងទន្លេសាប ដែលនឹងត្រូវបានចែកចាយយ៉ាងទូលាយ និងរក្សាទុកនៅក្នុងគេហទំព័រ (website) មួយសម្រាប់ គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ហើយអាចតភ្ជាប់ទៅនឹងគេហទំព័រពាក់ព័ន្ធដទៃៗទៀត។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ក្រសួងអភិវឌ្ឍន៍ជនបទ នឹងត្រូវបានជ្រើសរើសជាស្ថាប័នប្រតិបត្តិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយម។ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង នឹងត្រូវបានជ្រើសរើសជាស្ថាប័នអនុវត្ត។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:** ចាប់តាំងពីឆ្នាំ ១៩៩៥ មក អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ បានសាកល្បងការគ្រប់គ្រងធនធានធម្មជាតិក្នុងលក្ខណៈចូលរួមនៅក្នុងអាងបឹងទន្លេសាប រួមមានការសិក្សាសង្គម-សេដ្ឋកិច្ចនៃការធ្វើនេសាទ និងសហគមន៍នៅតាមតំបន់ព្រំដែន កិច្ចអភិវឌ្ឍន៍ និងការអនុវត្តន៍ការគ្រប់គ្រងធនធានព្រៃឈើដោយសហគមន៍ និងការគ្រប់គ្រងធនធាន

ធម្មជាតិនៃសាទផ្អែកលើសហគមន៍។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្អែកលើធនធានធម្មជាតិ សម្រាប់តំបន់បឹងទន្លេសាប ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ១៩៩៨ ដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដោយសហការយ៉ាងជិតស្និទ្ធជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ ក្រោមជំនួយបច្ចេកទេសតំបន់សម្រាប់ការការពារ និងការគ្រប់គ្រងតំបន់សើមសំខាន់នៅក្នុងអាងទន្លេមេគង្គខាងក្រោម (ឆ្នាំ ១៩៩៨) ADB គាំទ្រការអង្កេតសង្គម-សេដ្ឋកិច្ច និង ការពិគ្រោះយោបល់ដ៏ច្រើនជាមួយសហគមន៍មូលដ្ឋាន និងតំណាងរដ្ឋាភិបាល លើតម្រូវការនៃកិច្ចអភិវឌ្ឍន៍ជនបទដើម្បីកាត់បន្ថយភាពក្រីក្រ។ ចាប់តាំងពីឆ្នាំ ២០០២ មក ទស្សនៈយុទ្ធសាស្ត្រដែលត្រូវបានសម្រួលដោយយុទ្ធសាស្ត្របឹងទន្លេសាបរបស់ ADB ដែលទទួលស្គាល់ថាការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងជីវៈចម្រុះគប្បីត្រូវបានពិចារណាដោយឈរលើទស្សនៈនៃទីជម្រាលត្រង់ទឹកដែលចាក់ចូលទៅក្នុងបឹងទន្លេសាប បានអនុញ្ញាតឱ្យមានការវិភាគជាបន្តបន្ទាប់លើអាង។ ការយកចិត្តទុកដាក់ត្រូវ បានផ្តោតលើអន្តរាគមន៍ដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រតាមរយៈការកែលំអរលទ្ធភាពទទួលបាននូវជីវភាពប្រកបដោយចីរភាព ដោយយកចិត្តទុកដាក់ជាពិសេស ចំពោះស្ត្រីនិងសមាជិកនៃក្រុមជនជាតិភាគតិច។ ប្រការនេះគឺត្រូវមានការចូលរួមយ៉ាងជិតស្និទ្ធរវាងអ្នកផ្តល់ជំនួយ និងការបង្កើតភាពជាដៃគូដ៏មានប្រសិទ្ធិភាពនៅថ្នាក់លើ កណ្តាលក្រោម និងបង្កើននូវការចូលរួមយ៉ាងសកម្មពីសង្គមនានា។ NGOs ជាច្រើន ក៏ចូលរួមយ៉ាងសកម្មផងដែរនៅក្នុងការកែលំអរសេវាកម្មសង្គមនៅក្នុងតំបន់កណត់របស់គំរោង និងត្រូវបានពិគ្រោះយោបល់យ៉ាងទៀងទាត់ក្នុងអំឡុងពេលរៀបចំគម្រោង។ ពួកគេ អាចនឹងត្រូវជាបង្អែកផងដែរនៅក្នុងការផ្តល់សេវាកម្មជាក់លាក់ក្នុងអំឡុងពេលអនុវត្តគម្រោង។

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៏ៈ**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់ៈ ឆ្នាំ ២០០៤

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទានៈ ២០០៧

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង)ៈ ២០០៥

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង)ៈ មិនទាក់ទង

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទានៈ ២០០៧-២០១១

មិនមែនជាកម្ចីឥណទាន ៖ ៨ ខែ

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

| |
|---|
| ☐ ធនធានទុនធម្មតា:<br>☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ២០ លានដុល្លារ ។<br>☐ ផ្សេងទៀត:<br>ប្រសិនបើចាំបាច់មានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពដែលស្នើសុំ: ៣ លានដុល្លារ ពី AFD |
| ខ. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ថវិការដ្ឋបាលរបស់ ADB:<br>☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស: ៨00.000ដុល្លារ<br>☒ ផ្សេងទៀត: ៣00.000ដុល្លារ<br><br>ប្រសិនបើចាំបាច់មានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពដែលស្នើសុំ: មិនទាន់សម្រេច |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្រ្តនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្រ្តនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៥.២: គម្រោងអភិវឌ្ឍន៍និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☒ ប្រភេទកម្ចីឥណទាន
  - ☒ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☒ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ដឹកជញ្ជូន

អនុវិស័យ: ផ្លូវ

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ច
☐ ប្រជាភិវឌ្ឍន៍
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍
☐ អភិបាលកិច្ចល្អ
☐ ការការពារបរិស្ថាន
☒ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☒ កិច្ចសហប្រតិបត្តិការតំបន់
☐ ការការពារសង្គម
☐ ផ្សេងទៀត

ប្រធានបទរង:

**៣. វិសាលភាពគ្របដណ្តប់**

☐ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកហេដ្ឋារចនាសម្ព័ន្ធ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** Y. Tanaka អ្នកឯកទេសការងារដឹកជញ្ជូន

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** វិស័យផ្លូវបានរងការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ហើយបណ្តាញផ្លូវភាគច្រើនត្រូវបានចាត់ទុកថាធ្វើដំណើរមិនបាន។ ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ មក ADB ធនាគារពិភពលោក និងទីភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀតបានវិនិយោគធនធានដ៏ច្រើនលើការស្តារឡើងវិញនូវបណ្តាញផ្លូវជាតិលំដាប់ទីមួយ។ ជាលទ្ធផល មកដល់ពេលនេះ បណ្តាញធ្វើដំណើរសំខាន់ៗភាគច្រើននៃប្រទេស ត្រូវបានបង្កើតឡើងវិញ ឬ ស្ថិតនៅក្នុងតំណាក់កាលនៃការបង្កើតឡើងវិញតាមរយៈគម្រោងសន្យាទាំងឡាយ។ ដូចគ្នានេះដែរ ទីភ្នាក់ងារអភិវឌ្ឍន៍ទាំងឡាយ និងរាជរដ្ឋាភិបាលបានចំណាយធនធានដ៏ច្រើនលើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជនបទ រួមទាំងផ្លូវជនបទ ដើម្បីសម្រួលដល់ការតាំងទីលំនៅនៃប្រជាជនផ្លាស់ទីលំនៅជាច្រើន និងការស្តារកសិកម្មឡើងវិញ។ ពេលនេះ បណ្តាញផ្លូវលំដាប់មធ្យមប្រហែលជា ៨.000 គីឡូម៉ែត្រ ដែលរួមមានផ្លូវជាតិលំដាប់ទីពីរ និងផ្លូវខេត្ត ត្រូវការការយកចិត្តទុកដាក់។

ការថែទាំផ្លូវ មិនបានទាន់ការស្តារបណ្តាញផ្លូវនៅឡើយ។ ថ្វីបើគេបានបោះជំហានទីមួយរួចហើយក្តី ដោយបង្កើតមូលនិធិសម្រាប់ការជួសជុលនិងការថែទាំផ្លូវ ក៏មូលនិធិនេះ មិនមែនជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់សម្រាប់ធានាឱ្យបាននូវកម្មវិធីថែទាំប្រកបដោយចីរភាពឡើយ។ គេចាំបាច់ ត្រូវមាននីតិវិធីស្ថាប័នច្បាស់លាស់ ដើម្បីធ្វើផែនការ និងកំណត់អាទិភាពការងារថែទាំឱ្យមានប្រសិទ្ធិភាព ក៏ដូចជានីតិវិធីប្រកបដោយប្រសិទ្ធិភាពសម្រាប់គ្រប់គ្រង និងបញ្ចេញ

មូលនិធិផងដែរ។ យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍មូលនិធិថែទាំផ្លូវឱ្យកាន់តែមានប្រសិទ្ធិភាព នឹងតម្រូវឱ្យមាន (១) ការពង្រីកនិងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវមូលដ្ឋានចំណូលសម្រាប់មូលនិធិ (២) ការធានាឱ្យបាននូវលទ្ធភាពទទួលធនធានមូលនិធិ និង (៣) ការកសាងនិងការពង្រឹងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការធ្វើផែនការ និងការផ្តល់សេវាកម្មថែទាំផ្លូវ។ លើសពីនេះទៀត មន្ត្រីរដ្ឋាភិបាលនិងអ្នកម៉ៅការក្នុងស្រុកគប្បីត្រូវបានលើកទឹកចិត្តឱ្យទទួលធ្វើការងារថែទាំផ្លូវដោយផ្អែកលើកិច្ចសន្យា។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃគម្រោងអភិវឌ្ឍន៍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលត្រូវបានស្នើឡើងនេះ គឺដើម្បីស្តារបណ្តាញភូមិសាស្ត្រដ៏មានកម្រិតនៃផ្លូវជាតិលំដាប់ទីពីរ ជាមួយនឹងគោលបំណងបង្កើតឡើងវិញនូវការតភ្ជាប់គ្នាប្រកបដោយលក្ខណៈសន្សំសំចៃនៅក្នុងចំណោមបណ្តាញផ្លូវនិងបណ្តាញស្នូលនៃផ្លូវជាតិលំដាប់ទីមួយ។ គម្រោងនេះ នឹងជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតំបន់ជនបទ ដោយផ្តល់លទ្ធភាពធ្វើដំណើរប្រកបដោយលក្ខណៈសន្សំសំចៃ គ្រប់រដូវ និងគ្រប់ពេលវេលាទៅកាន់ទីផ្សារនិងការងារ និងជម្រុញកិច្ចអភិវឌ្ឍន៍សង្គម ដោយកាត់បន្ថយភាពដាច់ស្រយាល និងដោយផ្តល់លទ្ធភាពទទួលសេវាកម្មសង្គម។ ទំហំភូមិសាស្ត្រគម្រោង នឹងជួយធានាឱ្យបានថា អត្ថប្រយោជន៍នឹងទៅដល់ក្រុមមុខព្រួញដែលគេចង់បាន: ជាទូទៅ គ្រួសារនៅជនបទ និងដោយឡែកប្រជាជនប្តូរទីលំនៅ។

គម្រោងនេះ មានបំណងធានាឱ្យបាននូវការថែទាំផ្លូវប្រកបដោយចីរភាព ដោយប្រើមូលនិធិសម្រាប់ការជួសជុលនិងការថែទាំផ្លូវ។ គេរំពឹងថា រចនាសម្ព័ន្ធស្ថាប័នរបស់រាជរដ្ឋាភិបាលសម្រាប់ការធ្វើផែនការ និងការផ្តល់សេវាកម្មថែទាំផ្លូវ នឹងត្រូវបានកសាងនិងពង្រឹង និងថាជំនាញថែទាំផ្លូវរបស់អ្នកម៉ៅការក្នុងស្រុក និងប្រសិទ្ធិភាពចំណាយនៃការងារថែទាំផ្លូវនឹងត្រូវបានកែលំអរតាមរយៈកិច្ចសន្យារវាងរដ្ឋាភិបាលនៅមូលដ្ឋាន និងអ្នកម៉ៅការក្នុងស្រុកក្រោមគម្រោង។

គ. **សមាសភាគ និង សមិទ្ធិផល:** សមាសភាគចំបងនៃគម្រោងគឺ: (១) ការស្តារឡើងវិញនូវកំណាត់ផ្លូវប្រវែង ១៧ គម នៃផ្លូវជាតិលេខ ៣៣ ពីកំពង់ត្រាចទៅដល់ព្រំដែនកម្ពុជា-វៀតណាម ដែលគឺជាផ្នែកដ៏សំខាន់មួយនៃច្រករបៀងឆ្នេរសមុទ្រភាគខាងត្បូងនៃ GMS និងការកែលំអរបរិក្ខារឆ្លងកាត់ព្រំដែន (២) ការស្តារឡើងវិញនូវកំណាត់ផ្លូវប្រវែង ១៤ គម នៃផ្លូវជាតិលេខ ៧២ ពីផ្លូវបំបែកផ្លូវជាតិលេខ ៧ ទៅដល់ព្រំដែនកម្ពុជា-វៀតណាម និង ការកែលំអរបរិក្ខារឆ្លងកាត់ព្រំដែន (៣) ការចាក់ក្រាលថ្មល់កំណាត់ផ្លូវប្រវែង ១១៤ គម នៃផ្លូវជាតិលេខ ៥៦ ពីស៊ីសុផុនទៅដល់សំរោង និង (៤) ការដោះមីននិងការបោសសំអាតគ្រាប់បែកមិនទាន់ផ្ទុះនៅតាមតំបន់ខ្លះៗនៅជុំវិញផ្លូវ ដើម្បីអនុញ្ញាតឱ្យមានការតាំងទីលំនៅឡើងវិញ។

សមាសភាគទីពីរនៃគម្រោង គឺការថែទាំផ្លូវ។ ផែនការថែទាំផ្លូវប្រចាំឆ្នាំ នឹងត្រូវបានរៀបចំឡើងដោយស្ថានប័នប្រតិបត្តិគម្រោង ហើយការងារថែទាំទៀងទាត់ប្រចាំឆ្នាំ នឹងត្រូវបានអនុវត្តដោយប្រើមូលនិធិឥណទាន និងមូលនិធិសម្រាប់ការជួសជុល និងការថែទាំផ្លូវក្រោមកិច្ចសន្យារវាងរដ្ឋាភិបាលមូលដ្ឋាន និងអ្នកម៉ៅការក្នុងស្រុក។

គម្រោងនេះ ក៏នឹងរួមមានផងដែរនូវសមាសភាគអភិវឌ្ឍន៍សង្គម ដើម្បីគាំទ្រការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃបណ្ដាញផ្លូវដែលត្រូវបានស្ដារឡើងវិញ និងកាត់បន្ថយផលប៉ះពាល់សង្គមជាអវិជ្ជមាន ដែលអាចកើតឡើង និងសមាសភាគស្ថាប័នមួយ ដែលដោះស្រាយការថែទាំផ្លូវ និងសុវត្ថិភាពផ្លូវ ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** គម្រោងវិនិយោគមួយ ជាមួយនឹងសមាសភាគពាក់ព័ន្ធដែលកែលំអរប្រសិទ្ធិភាពវិស័យ និងសមត្ថភាពស្ថាប័ន លុបបំបាត់ឧបសគ្គដឹកជញ្ជូនទៅកាន់-មកពី និងនៅក្នុងតំបន់ជនបទជម្រើសមួយចំនួន។ លើសពីនេះទៀត ការធ្វើផែនការនិងការផ្ដល់ការថែទាំផ្លូវដោយរដ្ឋបាលមូលដ្ឋាន នឹងត្រូវបានពង្រឹងតាមរយៈការអនុវត្តន៍កិច្ចសន្យាការងារថែទាំជាមួយនឹងអ្នកម៉ៅការក្នុងស្រុក។ ជំនាញថែទាំផ្លូវរបស់អ្នកម៉ៅការក្នុងស្រុកនឹងត្រូវបានកែលំអរ ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ច ឬបរិស្ថាន:** ជំនួយបច្ចេកទេសត្រៀមរៀបចំគម្រោងសម្រាប់គម្រោងអភិវឌ្ឍន៍ នឹងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន នឹងពិនិត្យមើលបញ្ហាខាងសង្គមកិច្ច និងបរិស្ថានដែលទាក់ទិននឹងគម្រោង ។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** គម្រោងនេះ នឹងរៀបចំរបាយការណ៍ទាំងឡាយ ដែលរួមមានការវិភាគខាងវិស្វកម្ម សង្គមកិច្ច បរិស្ថាន និងសេដ្ឋកិច្ច ដែលនឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ គម្រោង នឹងរួមមានព័តិមានផ្ទាល់ សម្រាប់ភាគីពាក់ព័ន្ធទាំងឡាយស្ដីពីបញ្ហាទាក់ទិននឹងការអនុវត្តន៍គម្រោងស្ដារផ្លូវឡើងវិញនេះ និងសមាសភាគពាក់ព័ន្ធនៃកិច្ចអភិវឌ្ឍន៍សង្គម ។ ជាចុងក្រោយ គម្រោង នឹងផ្ដល់នូវកិច្ចអភិវឌ្ឍន៍ស្ថាប័ន និងការបណ្ដុះបណ្ដាលជូនអ្នកម៉ៅការក្នុងស្រុក និងបុគ្គលិករដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត ដើម្បីអាចឱ្យមានការថែទាំផ្លូវនាពេលអនាគត ។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ក្រសួងសាធារណៈការ និងដឹកជញ្ជូន ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:** មិនទាក់ទង ។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០២

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៦

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): ២០០៥

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង)៖

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន៖ ២០០៧-២០០៩

មិនមែនជាកម្ចីឥណទាន៖ ២០០៦

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា៖

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី៖ ៣៥ លានដុល្លារ។

☒ ផ្សេងទៀត៖ រាជរដ្ឋាភិបាល ១០ លានដុល្លារ អ្នកផ្តល់ហិរញ្ញប្បទានរួមមិនទាន់សម្រេច។

| ប្រភព | ចំនួន (លានដុល្លារ) |
|---|---|
| ហិរញ្ញប្បទាន ADB | ៣៥,០ |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ១០,៥ |
| ហិរញ្ញប្បទានផ្សេងទៀត | មិនទាន់សម្រេច |
| **ចំណាយសរុប** | **មិនទាន់សម្រេច** |

ប្រភព៖ ការប៉ាន់ស្មានរបស់ ADB។

ខ. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB៖

☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស៖ ១.០០០.០០០ដុល្លារ

☐ ផ្សេងទៀត៖

ប្រសិនបើចាំបាច់មានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពដែលស្នើសុំ៖ មិនទាន់សម្រេច

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស GMS = មហាអនុតំបន់មេគង្គ NR = ផ្លូវជាតិ RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការ ប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៥.៣: ការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាបទី ៣

## ឯកសារគោលគំនិត

កាលបរិច្ឆេទ: ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៤

១. ប្រភេទ/ទម្រង់នៃជំនួយ

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☒ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

២. មុខព្រួញជំនួយ

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: កសិកម្ម និង ធនធានធម្មជាតិ

អនុវិស័យ: បរិស្ថាន

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

| |
|---|
| ប្រធានបទ<br>☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន<br>☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់<br>☒ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន<br>☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍<br>ប្រធានបទរង: កិច្ចអភិវឌ្ឍន៍តំបន់ជនបទ ការចូលរួមរបស់សង្គមស៊ីវិល អភិរក្សធនធានធម្មជាតិ |
| **៣. វិសាលភាពគបដណ្តប់**<br>☒ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់<br>☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ |
| **៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ |
| **៥. មន្ត្រី ADB ទទួលបន្ទុក:** O. Sarrat អ្នកសេដ្ឋកិច្ចគម្រោងជាន់ខ្ពស់ (ធនធានធម្មជាតិ) |
| **៦. ពិពណ៌នាអំពីជំនួយ**<br>ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** ស្របតាមកម្មវិធីដែលត្រូវបានអនុម័តនៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូដើម្បីកាត់បន្ថយភាពក្រីក្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង ADB[1] យុទ្ធសាស្ត្រនិងកម្មវិធីសម្រាប់កម្ពុជាឆ្នាំ ២០០៥-២០០៧ នឹងផ្តោតការយកចិត្តទុកដាក់លើអាងបឹងទន្លេសាប។ ក្នុងខែ កក្កដា ឆ្នាំ ២០០៣ យុទ្ធសាស្ត្រអាងបឹងទន្លេសាបត្រូវបានបង្កើតឡើង[2] តាមរយៈយុទ្ធសាស្ត្រនិងកម្មវិធីសំរាប់ជួយកម្ពុជាឆ្នាំ ២០០៥-២០០៧។ ការគម្រាមកំហែងចំពោះបរិស្ថាន និងជីវៈចម្រុះនៃអាងបឹងទន្លេសាប ជាមូលហេតុនាំអោយកើតមានបញ្ហាជាច្រើន ហើយធ្ងន់ធ្ងរ ដែលនឹងត្រូវយកមកដោះស្រាយតាមរយៈគំរោងនេះ។ ការគម្រាមកំហែងចំពោះមុខ រួមមានការធ្វើអាជីវកម្មលើធនធានព្រៃឈើ ការទន្រ្ទានក្នុងរដូវប្រាំង និងការឆ្ការព្រៃលេចទឹក តម្រូវការធនធានកាន់តែច្រើនឡើងរបស់ប្រជាជនដែលកាន់តែកើនឡើង ការធ្វើអាជីវកម្មលើសលុបលើធនធានត្រីនិងធនធានសត្វព្រៃនៃ បឹងទន្លេសាប និងការប្រែប្រួលនៃគុណភាពទឹក និងកំរិតនៃការច្រោះដី។ ដោយទទួលស្គាល់នូវភាពស្មុគ្រស្មាញនៃភាពបំរែបំរួលនេះ |

[1] កិច្ចព្រមព្រៀងកំណត់ថាដៃគូរទាំងឡាយត្រូវរៀបចំយុទ្ធសាស្ត្រមួយសម្រាប់តំបន់បឹងទន្លេសាប ដោយយកចិត្តទុកដាក់លើការកែលំអចីរភាពនៃប្រព័ន្ធអេកូឡូស៊ីរបស់បឹងទន្លេសាប។

[2] ADB ។ ឆ្នាំ ២០០៣។ *ប្រយុទ្ធនឹងភាពក្រីក្រនៅកម្ពុជា: យុទ្ធសាស្ត្រអាងបឹងទន្លេសាប*។ ម៉ានីល។ គោលបំណងអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រអាងបឹងទន្លេសាបគឺដើម្បីបណ្តុះ ជម្រុញ និង សម្រួល (១) កំណើនសេដ្ឋកិច្ចសេដ្ឋកិច្ចប្រកបដោយចីរភាពដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រ (២) លទ្ធភាពទទួលទ្រព្យ និង (៣) ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន។

ADB បានសន្និដ្ឋានថា កិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងធនធានធម្មជាតិ គប្បី ត្រូវតែពិចារណាលើទស្សនៈរួមនៃអាងនេះ ដែលរួមមានខេត្ត-ក្រុងទាំងប្រាំបួន (ទូទាំងខេត្ត ឬផ្នែកខ្លះនៃខេត្តទាំង ៩) នៃខេត្តទាំង ២០ និងក្រុងទាំងបួននៃប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមរបស់ ADB គឺស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយទឹករបស់ខ្លួន និងនិន្នាការពិភពលោកទាំងមូលឆ្ពោះទៅកាន់ការគ្រប់គ្រងដីធ្លី ទឹក និងធនធានជីវៈ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃអាងទាំងមូល ដូចដែលត្រូវបានបង្ហាញតាមរយៈការបង្កើតស្ថាប័នសំរាប់បណ្តាញអន្តរជាតិនៃអាងដែលមានសមាជិកជាង ១៥០ ភាគច្រើន នៅអឺរ៉ុប អាមេរិកឡាទីន និងអាហ្វ្រិក។ ស្ថាប័នសំរាប់បណ្តាញនៃអាងទន្លេនៅអាស៊ី ក៏ត្រូវបានបង្កើតឡើងផងដែរ តាមរយៈគំនិតផ្តួចផ្តើមមួយរបស់ ADB ដើម្បីកែលំអរប្រសិទ្ធិភាពនៃស្ថាប័នគ្រប់គ្រងអាងក្នុងតំបន់ តាមរយៈការបង្កើនការផ្លាស់ប្តូរព័ត៌មានគ្នា កិច្ចសហប្រតិបត្តិការ និងសកម្មភាពសហការនានា។ ដើម្បីដោះស្រាយបញ្ហានៃការគម្រាមកំហែងលើបឹងទន្លេសាប តម្រូវឱ្យមានក្របខ័ណ្ឌស្ថាប័នរួមមួយដែលមានលក្ខណៈជាអន្តរវិស័យ និងអន្តរព្រំដែនដែលដំណើរការនៅកម្រិតនៃអាង។ បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) ដែលមានសមាជិកភាពនៃក្រសួងចំនួន ១០ និងផ្សារភ្ជាប់ជាមួយនឹងគណៈកម្មការទន្លេមេគង្គ (MRC) ទទួលបន្ទុកលើការជម្រុញការធ្វើផែនការអាង ដែលទទួលស្គាល់ភាពទាក់ទងគ្នានៃកត្តាសង្គមសេដ្ឋកិច្ច និងបរិស្ថាន។ ជាពិសេស និងជាការឆ្លើយតបទៅនឹងភាពចាំបាច់អោយមានការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋានមួយនៃតំបន់បម្រុងដែនជីវៈបឹងទន្លេសាប ត្រូវបានបង្កើតឡើងនៅក្នុង CNMC កាលពីខែ កញ្ញា ឆ្នាំ ២០០១។ ទោះបីជាយ៉ាងនេះក្តី ក៏ CNMC បានជួបការលំបាកនៅក្នុងការចាត់ចែងស្ថាប័នរបស់ខ្លួនដែរ។

ក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំឱ្យ ADB ផ្តល់ជំនួយបច្ចេកទេស (TA) ដើម្បីសិក្សាថា តើកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងអាងបឹងទន្លេសាបអាចត្រូវបានដឹកនាំ សម្របសម្រួល និងធ្វើការកែសំរួលឱ្យបានកាន់តែប្រសើរឡើងយ៉ាងដូចម្តេច។ ជាការឆ្លើយតប ADB បានអនុម័តជំនួយបច្ចេកទេសលេខ TA 42112-CAM: ការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាប[៣] ដើម្បីបំភ្លឺដល់តំរូវការនៃការរៀបចំស្ថាប័នដែលចាំបាច់សម្រាប់ការគ្រប់គ្រងអាង។ លទ្ធផលនៃជំនួយបច្ចេកទេសនេះ គឺ (១) គម្រោងការណ៏សម្រាប់កែលំអរការចាត់ចែងស្ថាប័នដើម្បីគ្រប់គ្រងទឹក និងធនធានធម្មជាតិពាក់ព័ន្ធនៃអាងបឹងទនេសាប ដែលរួមមានស្ថាប័នគ្រប់គ្រងអាងមួយ (២) ផែនការ ១០ ឆ្នាំសម្រាប់ឱ្យរាជរដ្ឋាភិបាល និង ADB សហការគ្នាដើម្បីអនុវត្តសំណើនេះ និងអភិវឌ្ឍវិធីសាស្ត្រសមាហរណកម្មមួយចំពោះការគ្រប់គ្រងធនធានទឹកនៅក្នុងអាងបឹងទន្លេសាប និង (៣) សំណើសុំ TA ថ្មីមួយដើម្បីចាប់ផ្តើមដំណើរការការងារនេះ។

[៣] TA 42112-CAM (ADB ។ ឆ្នាំ ២០០៣។ *ជំនួយបច្ចេកទេសចំពោះព្រះរាជាណាចក្រកម្ពុជាសម្រាប់: ការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាប*។ ម៉ានីល) ក្នុងទឹកប្រាក់ចំនួន ១៣៥.០០០ ដុល្លារ ដែលត្រូវបានអនុម័តនៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣។

[៤] គេហទំព័រនេះគឺ http://www.adb.org/Projects/tonle_sap/default.asp ។

ខ. **គោលដៅ និងគោលបំណង:** គោលដៅនៃ TA គឺការគ្រប់គ្រងដ៏ល្អលើធនធានធម្មជាតិ និងបរិស្ថាននៅក្នុងអាងបឹងទន្លេសាប។ គោលបំណងរបស់គម្រោង គឺដើម្បីជម្រុញការបង្កើតស្ថាប័នដ៏ល្អមួយ ដែលមានការចាត់ចែងត្រឹមត្រូវសម្រាប់ការគ្រប់គ្រងអាងនៅក្នុងអាងបឹងទន្លេសាប។

គ. **សមាសភាគ និង សមិទ្ធផល :** សមាសភាគ និងលទ្ធផលនៃ TA នឹងត្រូវបានកំណត់ផ្អែកលើសមិទ្ធផលរបស់ TA ការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាបទីពីរ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** លទ្ធផលនិងសិទ្ធិផលចំបងនៃ TA នឹងត្រូវបានលើកកំពស់តាមរយៈការចាត់ចែងស្ថាប័នសម្រាប់ការគ្រប់គ្រងអាង។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** គ្មានទំនាក់ទំនង

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** TA នេះ នឹងត្រូវបានផ្សាភ្ជាប់ទៅនឹងកម្មវិធីកំពុងដំណើរការរបស់សមាជិករបស់ CNMC ជាពិសេស កម្មវិធីរបស់ក្រសួងធនធានទឹកនិងឧតុនិយម និង MRC។ សមិទ្ធិផលរបស់គម្រោងនឹងត្រូវបានផ្សព្វផ្សាយតាមរយៈបណ្តាញព័ត៌មានរបស់ស្ថាប័នទាំងនេះ។ ADB ក៏បោះផ្សាយផងដែរ នូវព្រឹត្តិប័ត្រប្រចាំឆមាសអំពីការអនុវត្តន៍យុទ្ធសាស្ត្របឹងទន្លេសាប និងមានគេហទំព័រ (website) មួយសម្រាប់គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ដែលផ្តល់ការតភ្ជាប់ទៅគេហទំព័រពាក់ព័ន្ធផ្សេងៗ។[៤]

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬការចាប់បដិសន្ធិជំនួយ:** ក្នុងឆ្នាំ ២០០៣ CNMC បានចាប់ផ្តើមបញ្ចុះបញ្ចូលរដ្ឋាភិបាលនិងសហគមន៍មូលដ្ឋានឱ្យឈានឆ្ពោះទៅកាន់ទម្រង់ខ្លះនៃស្ថាប័នគ្រប់គ្រងអាងដែលស្របគ្នានឹងផែនការអភិវឌ្ឍន៍អាងរបស់ MRC។[៥] ក្រោយពេលនោះមក CNMC បានដើរតួនាទីជាស្ថាប័នប្រតិបត្តិសម្រាប់ TA នៃការបង្កើតស្ថាប័នគ្រប់គ្រងអាងបឹងទន្លេសាប។ តាមរយៈការពិភាក្សាយ៉ាងជិតស្និទ្ធជាមួយគ្នា ផែនការត្រួសត្រាយផ្លូវនៃការគ្រប់គ្រងអាងបឹងទន្លេសាប ត្រូវបានបង្កើតឡើង។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៤

[៥] MRC។ ឆ្នាំ ២០០២។ *របាយការណ៍តំបូងនៃផែនការអភិវឌ្ឍន៍អាង*។ រួមជាមួយនឹងកម្មវិធីប្រើប្រាស់ទឹក និង កម្មវិធីបរិស្ថាន ផែនការអភិវឌ្ឍន៍អាងគឺជាកម្មវិធីស្នូលមួយរបស់ MRC។ ផែនការនេះមានគោលបំណងបង្កើតក្របខ័ណ្ឌផែនការមួយនៃវិធាន គោលនយោបាយ និងនីតិវិធីដើម្បីធ្វើឱ្យមានតុល្យភាពដល់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព ជាមួយនឹងការការពារបរិស្ថាន និង ការជម្រុញឱ្យមានយុត្តិធម៌សង្គមនិងសមធម៌។

| |
|---|
| ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព<br><br>កម្ចីឥណទាន: មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង): ២00៥<br><br>គ. អំឡុងពេលនិងរយៈពេលនៃជំនួយ<br><br>កម្ចីឥណទាន : មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន : ៦ ខែ |
| ១0. **ផែនការហិរញ្ញប្បទាន**<br><br>ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ថវិការដ្ឋបាលរបស់ ADB:<br>☒ ផ្សេងទៀត: ហិរញ្ញប្បទានចំនួន ៣00.000 ដុល្លារ។ |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៩.៤: ការសិក្សាអំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធសំណង់លើការនេសាទនៃបឹងទន្លេសាប ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៤

១. ប្រភេទ/ទម្រង់នៃជំនួយ

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☒ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

២. មុខព្រួញជំនួយ

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: កសិកម្ម និង ធនធានធម្មជាតិ

អនុវិស័យ: បរិស្ថាន

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☒ ចីរភាពបរិស្ថាន
☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: កិច្ចអភិវឌ្ឍន៍តំបន់ជនបទ ក្រុមងាយរងគ្រោះដទៃទៀត អភិរក្សធនធានធម្មជាតិ

**៣. វិសាលភាពគ្របដណ្តប់**

☒ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** O. Sarrat អ្នកសេដ្ឋកិច្ចគម្រោងជាន់ខ្ពស់ (ធនធានធម្មជាតិ)

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** រចនាសម្ព័ន្ធសំណង់ផ្សេងៗ ដូចជា ទំនប់ ផ្លូវ និងប្រព័ន្ធគ្រប់គ្រងទឹកជំនន់ និងសំណង់បង្ការទឹកជំនន់ នាំមកនូវអត្ថប្រយោជន៍ខាងសង្គម និងសេដ្ឋកិច្ច។ ប៉ុន្តែសំណង់ទាំងនេះក៏អាចមានផលប៉ះពាល់យ៉ាងច្រើនផងដែរលើផ្នែកជលផល ដោយរារាំងដល់ការបំលាស់ទីរបស់ត្រី និងតំបន់ត្រីពងកែប្រែគុណភាពនិងបរិមាណទឹក កែប្រែទំនាក់ទំនងរវាងពេលវេលានិងទឹកន្លែងនៃធម្មជាតិរបស់វដ្តទឹកជំនន់ និងការធ្វើឱ្យខូចខាត ឬការធ្វើឱ្យបែកបាក់ដល់ជម្រកមច្ឆាជាតិ។ ការបាត់បង់ជម្រក អាចមានផលប៉ះពាល់ធ្ងន់ធ្ងរលើផលិតភាពនេសាទ។ រចនាសម្ព័ន្ធសំណង់ដទៃទៀត ដូចជា ប្រព័ន្ធលូទឹក រោងចក្រឧស្សាហកម្ម និងកម្មន្តសាលដែលបង្ហូរទឹកសំណល់ច្រើន និងការយករ៉ែនិងកែច្នៃរ៉ែ អាចធ្វើឱ្យខូចគុណភាពទឹកយ៉ាងច្រើន ដែលជាហេតុធ្វើឱ្យអន្តរាយដល់ផ្នែកជលផលទាំងមូល។ រចនាសម្ព័ន្ធសំណង់ ក៏អាចមានផលប៉ះពាល់ជាប្រយោលផងដែរ ឧទាហរណ៍ កិច្ចអភិវឌ្ឍន៍ធារាសាស្ត្រកសិកម្ម អាចនាំឱ្យមានការប្រើកាន់តែច្រើននូវសារធាតុគីមីសំរាប់កសិកម្ម រួមមានសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលនាំឱ្យអន្តរាយដល់ប្រព័ន្ធអេកូឡូស៊ីជលជាតិ និង អាចប៉ះពាល់ដល់គុណភាពនៃផលិតផលវារីវប្បកម្ម។ ប្រការដែលគួរឱ្យសោកស្តាយ បញ្ហាចំបងនោះ គឺថាការចូលរួមពីវិស័យនេសាទចំពោះសុខុមាលភាពសេដ្ឋកិច្ចនិងសង្គម និងសុខភាពរបស់ប្រជាជនរាប់លាននាក់ដែលពឹងផ្អែកលើការនេសាទ មិនត្រូវបានគេយល់ដឹងបានល្អឡើយ ហើយដោយហេតុនេះ វិស័យនេសាទត្រូវបានគេអោយតម្លៃយ៉ាងទាប។ TA នេះ នឹងបំពេញបន្ថែមលើគម្រោងឥណទាន និង TA មួយចំនួន (ក៏ដូចជាគម្រោងទាំងឡាយដែលនឹងត្រូវបានដាក់ជូនរដ្ឋាភិបាលជប៉ុន ដើម្បីសុំហិរញ្ញប្បទានក្រោមមូលនិធិជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ) ដែល ADB នឹងស្នើឡើង នៅក្នុងបរិបទនៃ

យុទ្ធសាស្ត្របឹងទន្លេសាប[១] ស្របគ្នានឹងយុទ្ធសាស្ត្រអាងបឹងទន្លេសាប។[២] TA នេះ នឹងសម្រួលការការពារវិនិយោគដែលកំពុងត្រូវបានធ្វើឡើង ដើម្បីអភិរក្សតំបន់ជីវៈបម្រុងបឹងទន្លេសាប (TSBR) និងដើម្បីលើកកំពស់ជីវភាពនៃសហគមន៍ទាំងឡាយដែលរស់នៅក្នុងតំបន់ជីវៈបម្រុងនេះ។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃ TA នេះ គឺការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពនូវធនធានធម្មជាតិជីវៈចម្រុះនៅក្នុងអាងបឹងទន្លេសាប។ គោលបំណងរបស់ TA គឺដើម្បីលើកកំពស់ការចេះដឹង និងការយល់ដឹងរបស់ស្ថាប័នរដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងសាធារណៈជនទូទៅ អំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធសំណង់នៅលើរបបជលសាស្ត្រនៃបឹងនេះ អំពីជីវភាពរបស់ប្រជាជនដែលពឹងផ្អែកលើការធ្វើនេសាទ និងជីវៈចម្រុះនៃបឹងទន្លេសាប និងដើម្បីលើកឡើងនូវសកម្មភាពចាំបាច់ទាំងឡាយដើម្បីសំរេចគោលបំណងនេះ។ TA នេះ នឹង (១) រៀបចំប្រព័ន្ធទិន្នន័យមួយអំពីរចនាសម្ព័ន្ធសំណង់មានស្រាប់ និងផលប៉ះពាល់របស់វា និង (២) រៀបចំយុទ្ធសាស្ត្រ និងសេចក្តីណែនាំដើម្បីធ្វើផែនការអន្តរាគមន៍ខាងស្ថាប័នដែលអាចមានផលប៉ះពាល់អវិជ្ជមានលើប្រព័ន្ធអេកូឡូស៊ី ឬ ជីវភាពនៅក្នុងតំបន់លិចទឹកនៃបឹងទន្លេសាប។ ការសិក្សានេះ នឹងពិនិត្យមើល TSBR និងប្រព័ន្ធទន្លេទាំងអស់នៅកម្ពុជាដែលប៉ះពាល់ដល់ប្រព័ន្ធធារាសាស្ត្ររបស់បឹងទន្លេសាប។ សមិទ្ធិផលរបស់ TA គឺប្រព័ន្ធទិន្នន័យមួយ ការវិភាគឡើងវិញយុទ្ធសាស្ត្រ និងសេចក្តីណែនាំជាយុទ្ធសាស្ត្រសម្រាប់កិច្ចអភិវឌ្ឍន៍រចនាសម្ព័ន្ធសំណង់ទាំងឡាយ ដែលមានលក្ខណៈអាចទទួលយកបាននៅក្នុងស្រុក លើកកំពស់ជម្រើសជីវភាព និងនាំមកនូវអត្ថប្រយោជន៍រយៈពេលវែងប្រកបដោយចីរភាព និងកម្មវិធីសកម្មភាពដែលជួយកែតម្រូវទៅតាមការចាំបាច់។

គ. **សមាសភាគ និងសមិទ្ធិផល:** TA នេះ នឹងត្រូវបានអនុវត្តនៅក្នុងពីរតំណាក់កាល។ នៅក្នុងតំណាក់កាលទីមួយ នឹងត្រូវមានការសិក្សាឡើងវិញ និងប្រមូលទិន្នន័យនិងព័ត៌មានទាំងអស់ អំពីរចនាសម្ព័ន្ធសំណង់មានស្រាប់ឬដែលបានគ្រោងដែលអាចជះឥទ្ធិពលទៅតាមពេលវេលា ទីកន្លែង និងគុណភាពនៃទឹកដែលហូរចាក់ចូលក្នុង (TSBR) ។ ជាពិសេសការវិភាគដ៏ស៊ីជម្រៅមួយ នឹងត្រូវបានធ្វើឡើងអំពីការវាយតម្លៃលើផលប៉ះពាល់បរិស្ថានដែលត្រូវបានធ្វើឡើង ដោយផ្សារភ្ជាប់ជាមួយនឹងការធ្វើផែនការ និងគម្រោងការណ៍នៃរចនាសម្ព័ន្ធសំណង់មានស្រាប់ឬដែលបានគ្រោង។ រចនាសម្ព័ន្ធសំណង់ទាំងនេះ រួមមាន ផ្លូវ ប្រព័ន្ធបង្ហូរទឹកចោល និងសំណង់គ្រប់គ្រងទឹកជំនន់ ប្រព័ន្ធធារាសាស្ត្រ កំពង់ទូក រចនាសម្ព័ន្ធបង្វែរទិស និងទំនប់។ ការសិក្សា នឹងធ្វើឡើងវិញដោយគម្រោងកំពុងដំណើរការ MRCS/WUP-FIN

---

[១] គំនិតផ្តួចផ្តើមបឹងទន្លេសាបគឺភាពជាដៃគូរមួយនៃស្ថាប័ននិងប្រជាជនទាំងឡាយដែលមានគោលបំណងឆ្លើយតបទៅនឹងចំណោទភាពក្រីក្រ-បរិស្ថាននៃបឹងទន្លេសាប ផ្អែកលើយុទ្ធសាស្ត្រអាងបឹងទន្លេសាប។

[២] ADB ។ ឆ្នាំ ២០០៣។ *ប្រយុទ្ធនឹងភាពក្រីក្រនៅកម្ពុជា: យុទ្ធសាស្ត្រអាងបឹងទន្លេសាប*។ ម៉ានីល។ គោលបំណងអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រអាងបឹងទន្លេសាបគឺដើម្បីបណ្តុះ ជម្រុញ និង សម្រួល (១) កំណើនសេដ្ឋកិច្ចសេដ្ឋកិច្ចប្រកបដោយចីរភាពដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រ (២) លទ្ធភាពទទួលទ្រព្យ និង (៣) ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន។

ម៉ូដែលបឹងទន្លេសាប និងផ្តល់យោបល់ដល់ការវិភាគអនុតំបន់បឹងទន្លេសាបរបស់គណៈកម្មការទន្លេមេគង្គ (MRC) ក្រោមកម្មវិធីអភិវឌ្ឍន៍អាងរបស់គណៈកម្មការនេះ។[៣] សកម្មភាពសំខាន់ៗដទៃទៀត នឹងរួមមានការពន្យល់លំអិតអំពីព័ត៌មានដែលមានស្រាប់ដែលជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធសំណង់ដែលមានស្រាប់ ឬដែលបានគ្រោងធ្វើដោយ TSBR ។ ចន្លោះប្រហោងនៃព័ត៌មានដែលមានស្រាប់ដែលរារាំងការវិភាគនេះ នឹងត្រូវបានកំណត់។ នៅក្នុងតំណាក់កាលទីពីរ កម្មវិធីមួយ នឹងត្រូវបានបង្កើត និងរៀបចំឡើងដើម្បីប្រមូលទិន្នន័យនិងព័ត៌មានដែលគេត្រូវការ ដើម្បីអាចធ្វើការព្យាករណ៍ឱ្យបានត្រឹមត្រូវអំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធសំណង់ទាំងឡាយ។ កម្មវិធី នឹងបញ្ចូលនូវកំណត់ត្រាជាក់លាក់មួយនៃការសិក្សាបន្ថែមដែលអាចជួយកែសំរួលនូវការវាយតម្លៃផលប៉ះពាល់បរិស្ថានមានស្រាប់ ដែលខកខានមិនបានដោះស្រាយនូវផលប៉ះពាល់លើ TSBR និងរៀបចំនូវប្រព័ន្ធតាមដានរយៈពេលវែងដែលចាំបាច់ត្រូវបង្កើតឡើង។ គេនឹងកត់ត្រាទុកនូវកំណត់សំគាល់នៃផលប៉ះពាល់ពីខាងក្រៅកម្ពុជា ដែលចាំបាច់ ត្រូវគិតគូរដល់ការការពារ TSBR ក្នុងរយៈពេលវែង។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** អ្នកពិគ្រោះការងារនឹងរួមមាន (១) អ្នកសេដ្ឋកិច្ចសង្គមម្នាក់ (សំរាប់ធ្វើការ ៥ខែ) ដែលមានបទពិសោធន៍ខាងទំនាក់ទំនងសហគមន៍ និងការវាយតម្លៃស្ថានភាពជនបទ (RRA) (២) វិស្វករជលវិទ្យា ឬជំនាញធារាសាស្ត្រម្នាក់ (សំរាប់ធ្វើការ ៥ខែ) ដែលមានបទពិសោធន៍ខាងធ្វើគម្រូលើប្រព័ន្ធទន្លេ (៣) អ្នកឯកទេសខាង ផលប៉ះពាល់បរិស្ថានម្នាក់ (សំរាប់ធ្វើការ ៤ខែ) ដែលមានបទពិសោធន៍ខាងដំណើរការ និងនីតិវិធីវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិមាណផលប៉ះពាល់លើប្រព័ន្ធអេកូឡូស៊ីជលជាតិ (៤) បរិស្ថានវិទូម្នាក់ (សំរាប់ការងារ ៥ខែ) (៥) អ្នកសេដ្ឋកិច្ចម្នាក់ (សំរាប់ការងារ ២ខែ) និង (៦) អ្នកធ្វើកម្មវិធីកុំព្យូទ័រប្រព័ន្ធទិន្នន័យ (សំរាប់ការងារ ១ខែ)។ អ្នកពិគ្រោះការងារទាំងនេះ នឹងផលិត (១) របាយការណ៍ចាប់ផ្តើមការងារក្នុងរយៈពេលបីសប្តាហ៍ក្រោយពេលចាប់ផ្តើម TA (២) របាយការណ៍តំណាក់កាលទីមួយក្នុងរយៈពេល ១២ សប្តាហ៍ (៣) សេចក្តីព្រាងរបាយការណ៍ចុងក្រោយក្នុងរយៈពេល ២០ សប្តាហ៍ និង (៤) របាយការណ៍ចុងក្រោយ។ ស្ថាប័នប្រតិបត្តិ នឹងបំពេញសំណួរអង្កេត TA មួយដោយខ្លួនឯងដើម្បីវាយតម្លៃវិការចំណាយ និងលទ្ធផលរបស់ TA ដកស្រង់បទពិសោធន៍ និងមេរៀនដែលបានអនុវត្តកន្លងមក និងស្នើឡើងនូវសកម្មភាពបន្ត។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ច ឬបរិស្ថាន:** បឹងទន្លេសាប គឺជាប្រព័ន្ធអេកូឡូស៊ីទឹកសាបដ៏មានផលិតភាពបំផុតមួយនៅក្នុងពិភពលោក ដែលតំណាងឱ្យការទទួលទានប្រូតេអ៊ីន ៤០-៧០% នៃប្រជាជនកម្ពុជា។ ហេតុនេះ វាគឺជាប្រការសំខាន់

---

[៣] ការសិក្សានឹងកសាងលើសមិទ្ធិផលនៃគម្រោងធ្វើគម្រូបឹងទន្លេសាប MRCS/WUP-FIN ដែលរដ្ឋាភិបាលហ្វាំងឡង់បន្តគាំទ្រ និង បង្ហាញបណ្តាវិធីជាក់ស្តែងដើម្បីបង្កើនជាអតិបរិមានូវទិន្នផលរបស់គម្រោងនោះ។

[៤] ADB ។ ឆ្នាំផ្សេងៗ។ *ដំណោះស្រាយអនាគតនាពេលនេះ: គំនិតផ្តួចផ្តើមបឹងទន្លេសាប*។ ម៉ានីល។

[៥] មាននៅ: http://www.adb.org/Projects/tonle_sap/default.asp

ដែលត្រូវយល់ដឹងឱ្យបានល្អ អំពីផលប៉ះពាល់នៃរចនាសម្ព័ន្ធសំណង់លើរបបជលសាស្ត្ររបស់បឹងទន្លេសាប ទាក់ទិននឹងជីវភាពរបស់ប្រជាជនដែលពឹងផ្អែកលើការនេសាទ និងជីវៈចម្រុះរបស់បឹងទន្លេសាប ។ TA នេះ នឹងមិនមានផលប៉ះពាល់អវិជ្ជមានខាងសង្គមឬបរិស្ថានអ្វីឡើយ ។ ផ្ទុយទៅវិញ TA នេះ នឹងជួយស្ថាប័នរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការកំណត់ផលប៉ះពាល់អវិជ្ជមានពីកិច្ចអភិវឌ្ឍន៍នៅក្នុងវិស័យដទៃទៀតលើការនេសាទនៃបឹងទន្លេសាប ដោយគូសបង្ហាញពីការពឹងផ្អែករបស់វិស័យទាំងនោះលើរបបជលសាស្ត្រធម្មជាតិរបស់បឹងទន្លេសាប និងជាយថាហេតុលើប្រជាជនដែលពឹងផ្អែកលើនេសាទនិងរបបជលសាស្ត្រធម្មជាតិនេះ ។ ផលប៉ះពាល់ដែលអាចមាននៃការថយចុះនៃធនធាននេសាទលើប្រជាជន រួមមាន (១) កំណើននៃការខ្វះខាតស្បៀងអាហារតាមរដូវ (២) កង្វះអាហារូបត្ថម្ភ (ប្រូតេអ៊ីន កាល្ស្យូម វីតាមីន) (៣) ការបាត់បង់ឱកាសការងារជាប្រពៃណី និង (៤) កំណើនចំណាកស្រុក ចូលទីក្រុង និង បញ្ហាសង្គម ។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** ការសិក្សានេះនឹងផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងកម្មវិធីមានស្រាប់របស់ MRC ក្រសួងបរិស្ថាន និង គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC) និង នឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយតាមរយៈបណ្ដាញព័ត៌មានរបស់ស្ថាប័នទាំងនេះ ។ សិក្ខាសាលាជាតិធំមួយនឹងត្រូវបានប្រារព្ធធ្វើឡើងនៅពេលបញ្ចប់ការសិក្សា ។ ជម្រើសយកលទ្ធផលពីការសិក្សាខ្លះៗ ដើម្បីបោះផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ ។ របាយការណ៍ដែលបង្ហាញនូវការពឹងផ្អែកយ៉ាងខ្លាំងរបស់ប្រជាជនលើការធ្វើនេសាទនៅក្នុងបឹងទន្លេសាប ដើម្បីជីវភាពរស់នៅ និងចំណូលបន្ថែមដែលពន្យល់អំពីលទ្ធភាពនៃផលប៉ះពាល់អវិជ្ជមានលើការនេសាទ មកពីកិច្ចអភិវឌ្ឍន៍នៅក្នុងវិស័យដទៃទៀត និងដែលបង្ហាញជម្រើសទាំងឡាយដើម្បីការពារផលិតភាពនេសាទ នឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយជូនស្ថាប័នរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ។ កូនសៀវភៅព័ត៌មានបច្ចេកទេសមានរូបភាព នឹងត្រូវបានរៀបចំឡើងសម្រាប់វិស័យសេដ្ឋកិច្ចនិមួយៗ ។ ADB ក៏បោះផ្សាយផងដែរនូវព្រឹត្តិប័ត្រព័ត៌មានប្រចាំឆមាស អំពីយុទ្ធសាស្ត្របឹងទន្លេសាប[៤] ដែលត្រូវផ្សព្វផ្សាយយ៉ាងទូលាយ និង មានគេហទំព័រ (website) មួយសម្រាប់គម្រោងគ្រប់គ្រងបរិស្ថានទន្លេសាប ។[៥]

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ស្ថាប័នប្រតិបត្តិ TA នេះ នឹងអាចជា CNMC ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិងឧតុនិយម និង ក្រសួងសាធារណៈការនិងដឹកជញ្ជូន ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:** នៅដើមឆ្នាំ ២00៣ បេសកកម្មរបស់ TA ដែលបានសិក្សារកការពិតមួយសម្រាប់គម្រោងជីវភាពប្រកបដោយចីរភាពនៅតំបន់បឹងទន្លេសាប បានធ្វើការពិភាក្សាជាមួយ MRC ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន ។ បេសកកម្មបានសន្និដ្ឋានថា ការសិក្សាដែលបានស្នើឡើងអំពីឥទ្ធិពលនៃរចនាសម្ព័ន្ធសំណង់លើការនេសាទនៃបឹងទន្លេសាប នឹងជួយកសាងមូលដ្ឋានចំណេះដឹងល្អ និងកំណត់លទ្ធភាពយុទ្ធសាស្ត្រនិងសកម្មភាព ដើម្បីទប់ទល់នឹងផលប៉ះពាល់អវិជ្ជមានទាំងឡាយ ។

| |
|---|
| **៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍៖**<br><br>ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់៖ ឆ្នាំ ២០០២៤<br><br>ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព<br><br>កម្ចីឥណទាន៖ មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង)៖ មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង)៖ ខែ ឧសភា ឆ្នាំ ២០០៥<br><br>គ. អំឡុងពេលនិងរយៈពេលនៃជំនួយ<br><br>កម្ចីឥណទាន ៖ មិនទាក់ទង<br>មិនមែនជាកម្ចីឥណទាន ៖ ៦ ខែ |
| **១០. ផែនការហិរញ្ញប្បទាន៖**<br><br>ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ថវិការដ្ឋបាលរបស់ ADB៖<br>☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស<br>☒ ផ្សេងទៀត៖ ហិរញ្ញប្បទានចំនួន ៣០០.០០០ ដុល្លារដោយស្ថាប័នឧបតោភាគី នឹងត្រូវបានសុំក្នុងអំឡុងពេលរៀបចំ TA នេះ។ |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស TASF = មូលនិធិពិសេសសម្រាប់ជំនួយបច្ចេកទេស។

## តារាង ក៥.៥: ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាបទី ២
## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☒ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: កសិកម្ម និង ធនធានធម្មជាតិ

អនុវិស័យ: នេសាទ

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

- ☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព
- ☒ ចីរភាពបរិស្ថាន

☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

**៣. វិសាលភាពគ្របដណ្ដប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកកសិកម្ម បរិស្ថាន និង ធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** O. Sarrat អ្នកសេដ្ឋកិច្ចគម្រោងជាន់ខ្ពស់ (ធនធានធម្មជាតិ)

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈ/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** ដោយគ្មានការសង្ស័យឡើយ នេសាទទឹកសាបគឺមានតួនាទីដ៏សំខាន់ចំពោះសន្តិសុខស្បៀង ចំណូល និង ការងាររបស់ប្រជាជនកម្ពុជា។[១] ទោះជាយ៉ាងនោះក្តី ក៏ការយកចិត្ត-ទុកដាក់កំពុងតែត្រូវបានទាក់ទាញទៅលើផលប៉ះពាល់នៃការធ្វើនេសាទលើសលុបនិងដែលមានលក្ខណៈបំផ្លិចបំផ្លាញ។ អតីតព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ បានព្រមានថា ប្រទេសកម្ពុជាប្រឈមមុខនឹងគ្រោះមហន្តរាយ បរិស្ថាន ប្រសិនបើប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបខូចខាតបន្ថែមទៀត។

ការស្រាវជ្រាវខាងជលផលអាចដំណើរការដើម្បី (១) ធ្វើឱ្យកាន់តែសម្បូរណ៍ត្រី (២) បន្ថែមលើពហុកម្មជលផល (៣) បង្កើតការងារនិងប្រាក់ចំណូលឱ្យអ្នកនេសាទ (៤) បង្កើតជម្រើសជីវភាព (៥) អភិរក្សនិងកសាងឡើងវិញនូវជង្រុកត្រី (៦) ផ្តល់ឱវាទខាងគោលនយោបាយលើការចាត់ចែងការងារគ្រប់គ្រងលើធនធានជលសាស្ត្ររួម ផ្អែកលើការយល់ច្បាស់លើកត្តាខាងក្រៅដែលប៉ះពាល់ដល់ការប្រើប្រាស់ធនធានទាំងនោះ (៧) គាំទ្រកិច្ចប្រឹងប្រែងរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានជលសាស្ត្រនិងការការពារជីវៈចម្រុះ។ ក្នុងន័យនេះ ការស្រាវជ្រាវអាចកាត់បន្ថយភាពក្រីក្រ និង ត្រូវបានគាំទ្រដោយគោលនយោបាយរបស់ ADB ស្តីពីនេសាទ[២] ដែលត្រូវបានដឹកនាំដោយគោលនយោបាយ របស់ ADB ស្តីពីកសិកម្មនិងការស្រាវជ្រាវអំពីធនធានធម្មជាតិ។[៣]

---

[១] ត្រីផ្តល់នូវការទទួលប្រូតេអ៊ីន ៤០-៧០% របស់ប្រជាជនកម្ពុជា និង នេសាទប្រចាំឆ្នាំនៅបឹងទន្លេសាបតំណាងឱ្យប្រហែលជា ៧៥% នៃនេសាទទឹកសាបជាតិ។ នេសាទនិងកសិកម្មគឺជាប្រភពសំខាន់ទាំងពីរនៃជីវភាពរបស់ប្រជាជនទាំងបីលាននាក់ (២៥% នៃប្រជាជនកម្ពុជា) ដែលរស់នៅជុំវិញបឹងទន្លេសាប។

[២] ADB។ ឆ្នាំ ១៩៩៧។ *គោលនយោបាយរបស់ធនាគារ*។ ម៉ានីឡា។

វិទ្យាស្ថានស្រាវជ្រាវស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (IFREDI) ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០០២ ជាអង្គភាពរូបវ័ន្ត ស្របច្បាប់ និងមានលក្ខណៈជាអង្គការមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយដ្ឋាននេសាទ (DOF) នៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ បេសកកម្មនៃវិទ្យាស្ថាននេះ គឺដើម្បីជម្រុញកិច្ចអភិវឌ្ឍន៍ចីរភាព និងការប្រើប្រាស់នូវធនធានជលសាស្ត្រដែលផ្អែកលើការគ្រប់គ្រងបរិស្ថានអោយបានល្អ។[៤] វិទ្យាស្ថាននេះ មានផ្នែកមួយសម្រាប់ការស្រាវជ្រាវខាងជីវសាស្ត្រ និងការវាយតម្លៃធនធាន និងផ្នែកមួយសម្រាប់ការស្រាវជ្រាវខាងសង្គមសេដ្ឋកិច្ច និងគ្រប់គ្រងស្ថានីយពិសោធន៍ចំនួនពីរ សម្រាប់ការនេសាទតាមបឹង និងការនេសាទប្រើមង។ កម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថាន ដែលត្រូវបានអនុវត្តដោយបុគ្គលិកស្រាវជ្រាវចំនួនប្រហែល ៣០ នាក់ដែលត្រូវបានចាត់ឱ្យធ្វើការឱ្យគម្រោងសម្រាប់ការគ្រប់គ្រងការនេសាទត្រីទឹកសាប ត្រូវបានរៀបចំឡើងរួចហើយ។ នៅក្នុងតំណាក់-កាលតំបូងនេះ គេឃើញមានឱកាសនៃការបង្កើតប្រព័ន្ធស្រាវជ្រាវដំណើរការបានល្អមួយដែលមានស្តង់ដារខ្ពស់ សម្រាប់កិច្ចប្រឹងប្រែងវិភាគ និងការរាយការណ៍ និងការផ្សព្វផ្សាយព័ត៌មានក្នុងលក្ខណៈវិទ្យាសាស្ត្រប្រកបដោយប្រសិទ្ធិភាព។ គឺជាសារៈសំខាន់ដែលត្រូវតែកសាងសមត្ថភាពសំរាប់ធ្វើផែនការ និងធ្វើការងារស្រាវជ្រាវ ពង្រីកនិងផ្សព្វផ្សាយរបកគំហើញនានាដែលចាប់ផ្តើមឡើងពីមូលដ្ឋានតូចឡើងទៅ។

កាលពីខែ វិច្ឆិកា ឆ្នាំ ២០០២ ADB បានអនុម័ត TA 4025–CAM: ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប។ គោលដៅនៃ TA នេះ គឺការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងជីវៈចម្រុះនៅក្នុងអាងបឹងទន្លេសាប។ គោលបំណងរបស់គម្រោង គឺដើម្បីចាប់ផ្តើមដំណើរការ IFREDI ជាវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ដ៏មានប្រសិទ្ធិភាព និងសមស្របមួយ។ លទ្ធផលនៃ TA នេះ គឺស្ថិតនៅក្នុងវិស័យនៃ (១) ការគ្រប់គ្រងវិទ្យាស្ថាន (២) ការស្រាវជ្រាវនិងកិច្ចអភិវឌ្ឍន៍ (៣) ការផ្ទេរបច្ចេកវិទ្យា និង (៤) កិច្ចអភិវឌ្ឍន៍និង

---

[៣] ADB។ ឆ្នាំ ១៩៩៧។ *គោលនយោបាយរបស់ធនាគារស្តីពីកសិកម្មនិងការស្រាវជ្រាវអំពីធនធានធម្មជាតិ*។ ម៉ានីល។

[៤] ភារៈកិច្ចរបស់ IFREDI រួមមាន (១) កំណត់និងឃ្លាំមើលការលូតលាស់របស់ត្រីទឹកសាបនិងធនធានធម្មជាតិមានជីវិតដទៃទៀតដែលមានសារៈសំខាន់ចំពោះសេដ្ឋកិច្ច សន្តិសុខស្បៀងអាហារ និង ការថែរក្សាជីវៈចម្រុះ (២) បង្កើតកម្មវិធីស្រាវជ្រាវអំពីនេសាទទឹកសាប និង ធ្វើការស្រាវជ្រាវលើប្រធានបទទាក់ទងនឹងទិដ្ឋភាពខាងអេកូឡូស៊ី ជីវសាស្ត្រ បច្ចេកទេស និង សង្គមសេដ្ឋកិច្ចនៃនេសាទ (៣) ស្រាវជ្រាវអំពីផលប៉ះពាល់នៃការសាងសង់ទំនប់ ប្រព័ន្ធធារាសាស្ត្រ និង សកម្មភាពអភិវឌ្ឍន៍ដទៃទៀត លើធនធានជលសាស្ត្រមានជីវិត (៤) បង្កើតប្រព័ន្ធទុកដាក់ព័ត៌មាន (៥) ផ្សព្វផ្សាយព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកទេសដើម្បីលើកកំពស់ការយល់ដឹងអំពីភាពចាំបាច់នៃអភិរក្ស និង ជម្រើសទាំងឡាយនៃការងារគ្រប់គ្រង (៦) ស្រាវជ្រាវអំពីទំនាក់ទំនងរវាងនេសាទទឹកសាបនិងវារីវប្បកម្ម (៧) ផ្តល់ការបណ្តុះបណ្តាលអំពីនេសាទទឹកសាប និង ការគ្រប់គ្រងនេសាទទឹកសាប (៨) ធ្វើសហប្រតិបត្តិការជាមួយអង្គការនៅតាមមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលនិងអន្តរជាតិ និង (៩) ចូលរួមនៅក្នុងសកម្មភាពរកចំណូលទាំងឡាយទាក់ទិននឹងរបៀបវារៈស្រាវជ្រាវ។

[៥] ADB។ ឆ្នាំផ្សេងៗ។ *ដំណោះស្រាយអនាគតនាពេលនេះ: គំនិតផ្តួចផ្តើមបឹងទន្លេសាប*។ ម៉ានីល។

[៦] មាននៅ: http://www.adb.org/Projects/tonle_sap/default.asp

ការពិភាក្សាគោលនយោបាយ ។ TA នេះ គឺអនុវត្តជិតដល់ទីបញ្ចប់ហើយ និងបានទទួលជោគជ័យខ្ពស់ ។ TA នេះ ប្រសិនបើទោះបីជាមិនបានបង្កើតសមត្ថភាពថ្មីក្តី ក៏បាននាំឱ្យមានការកែលំអសមត្ថភាពច្រើនដែរ ។ ភាគីពាក់ព័ន្ធទាំងអស់បានបង្ហាញការពេញចិត្តច្រើនចំពោះគុណភាព និងកម្រិតនៃសមិទ្ធិផល ។ ជាពិសេស គណៈកម្មការទន្លេមេគង្គ បានកត់សំគាល់ថា សមិទ្ធិផលនៃ TA នេះ បានបង្ហាញច្បាស់នៅក្នុងការសម្រេចចិត្តដ៏ពេញលេញ ក្នុងការផ្តល់មូលនិធិជូនដល់ការសាងសង់ IFREDI ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីកសាងសមត្ថភាពសម្រាប់ការងារគ្រប់គ្រងនេសាទទឹកសាបនៅក្នុងអាងទន្លេមេគង្គ ។ ទោះជាយ៉ាងណាក្តី ក៏នៅមានការងារដែលត្រូវធ្វើជាបន្តទៀតដែរ ។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃ TA នេះ គឺការគ្រប់គ្រង និងអភិរក្សប្រកបដោយចីរភាពនូវធនធានធម្មជាតិ និងជីវៈម្រុះនៅក្នុងអាងបឹងទន្លេសាប ។ គោលបំណងរបស់គម្រោង គឺដើម្បីចាប់ផ្តើម IFREDI ជាវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ដ៏មានប្រសិទ្ធិភាព និងសមស្របមួយ ។

គ. **សមាសភាគ និង សមិទ្ធិផល:** លទ្ធផលនៃ TA នេះ គឺស្ថិតនៅក្នុងវិស័យនៃ (១) ការផ្ទេរបច្ចេកវិទ្យា និង (២) កិច្ចអភិវឌ្ឍន៍ និងការពិភាក្សាគោលនយោបាយ ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** លទ្ធផលនិងសមិទ្ធិផលចំបង គឺការលើកកំពស់សមត្ថភាពផ្សព្វផ្សាយផ្លែផ្កានៃការស្រាវជ្រាវ និងកិច្ចអភិវឌ្ឍន៍ជលផលនៅក្នុងប្រទេសកម្ពុជា ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** គ្មាន

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** TA នេះ នឹងផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងកម្មវិធីមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ សមិទ្ធិផលរបស់ TA នឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយតាមរយៈបណ្តាញព័ត៌មានរបស់ក្រសួង ជាពិសេស តាមរយៈគេហទំព័រ (website) ថ្មីរបស់ IFREDI ។ ADB ក៏បោះផ្សាយផងដែរនូវព្រឹត្តិប័ត្រព័ត៌មានប្រចាំឆមាសអំពីយុទសាស្រ្តបឹងទន្លេសាប[៥] និងមានគេហទំព័រ (website) មួយសម្រាប់គម្រោងគ្រប់គ្រងបរិស្ថានទន្លេសាបដែលផ្តល់ការតភ្ជាប់ទៅនឹងគេហទំព័រពាក់ព័ន្ធផ្សេងៗ ។[៦]

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ស្ថាប័នប្រតិបត្តិសម្រាប់ TA នេះ នឹងអាចជានាយកដ្ឋានជលផល

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬ ការចាប់បដិសន្ធិជំនួយ:**

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៥

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

| |
|---|
| កម្ចីឥណទាន: ២០០៥<br>មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង):<br>មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):<br><br>គ. អំឡុងពេល និង រយៈពេលនៃជំនួយ<br><br>កម្ចីឥណទាន :<br>មិនមែនជាកម្ចីឥណទាន : ៦ ខែ |
| ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ចរិការរដ្ឋបាលរបស់ ADB:<br>☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស: ៣០០.០០០ ដុល្លារ<br>☐ ផ្សេងទៀត: |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៥.៦: ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុទី ១ ( អនុកម្មវិធីទី៣)

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☒ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: វិស័យហិរញ្ញវត្ថុ

អនុវិស័យ:

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់

☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

**៣. វិសាលភាពគ្របដណ្តប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកអភិបាលកិច្ច ហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** S. Tukuafu អ្នកឯកទេសហិរញ្ញវត្ថុ

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈ/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** សេដ្ឋកិច្ចនៃប្រទេសកម្ពុជា បង្ហាញអន្តរការិយកម្មហិរញ្ញវត្ថុនៅមានកម្រិត ទំនុកចិត្តសាធារណៈលើធនាគារក៏ទាប និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារមួយចំនួននៅក្មេងខ្ចី។ ប្រព័ន្ធហិរញ្ញវត្ថុពុំទាន់អភិវឌ្ឍន៍ពេញលេញ គឺជាឧបសគ្គគន្លឹះចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងដែលមានមូលដ្ឋានធំទូលាយ ហើយក៏ជាហេតុរាំងដល់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចចំបងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ ដូចគ្នានិងប្រព័ន្ធពាណិជ្ជកម្មកំពុងអភិវឌ្ឍដ៏ក្មេងខ្ចីដទៃទៀតដែរ វិស័យហិរញ្ញវត្ថុត្រូវបានរាំងដោយ (១) ហានិភ័យខ្ពស់ពាក់ព័ន្ធនឹងធនាគារទន់ខ្សោយ និង ភាពមិនប្រាកដប្រជានៃការដាក់ឱ្យអនុវត្តកិច្ចសន្យានិងទ្រព្យធានា (២) ចំណាយលើព័ត៌មានខ្ពស់ដែលបណ្តាលមកពីកង្វះប្រព័ន្ធគណនេយ្យ ស្តង់ដារគណនេយ្យនិងសវនកម្មសមស្រប និង ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានដទៃទៀត (៣) ចំណាយប្រតិបត្តិការខ្ពស់ដោយសារភាពទន់ខ្សោយនៅក្នុងប្រព័ន្ធទូទាត់ ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល និង ផ្នែកដទៃទៀតនៃហេដ្ឋារចនាសម្ព័ន្ធទីផ្សារ (៤) គ្រឹះស្ថានហិរញ្ញវត្ថុរដ្ឋគ្មានប្រសិទ្ធិភាព និង (៥) ប្រព័ន្ធនិងសមត្ថភាពត្រួតពិនិត្យទន់ខ្សោយ។

រាជរដ្ឋាភិបាលបានអភិវឌ្ឍយុទ្ធសាស្ត្រវិស័យរបស់ខ្លួន ដោយរៀបចំចក្ខុវិស័យផែនការវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០ ដោយមានការជួយគាំទ្រពី ADB។ គម្រោងកាត់បន្ថយភាពក្រីក្រ និងកំណើនរបស់ IMF (PRGF) បានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៩ បានពង្រឹងការត្រួតពិនិត្យធនាគារ និង បានរៀបចំរចនាសម្ព័ន្ធឧស្សាហកម្មធនាគារឡើងវិញ។ ឥណទានកម្មវិធីវិស័យហិរញ្ញវត្ថុ (FSPL I) បានបំពេញបន្ថែមលើកម្មវិធីរបស់ IMF ស្តីពីការត្រួត

ពិនិត្យ និងបានផ្តល់ផងដែរនូវជំនួយដល់វិស័យធានារ៉ាប់រង ទីផ្សាររូបិយវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ។ FSPL I ដែលផ្អែកលើចង្កោមឥណទាននៃអនុកម្មវិធីចំនួនបី ត្រូវបានអនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ ២០០១ រួមជាមួយនិងអនុកម្មវិធីទី ១ ដែលមានទឹកប្រាក់ចំនួន ១០ លានដុល្លារ។ ក្រោយពេលបញ្ចប់ប្រកបដោយជោគជ័យនូវអនុកម្មវិធីទី ១ ADB បានអនុម័តអនុកម្មវិធីទី ២ នៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០២។ ការអនុវត្តន៍សកម្មភាពទាំងឡាយក្រោមអនុកម្មវិធីទី ២ គឺស្ថិតក្នុងតំណាក់កាលវិវឌ្ឍន៍ បោះជំហានទៅមុខជិតដល់ទីបញ្ចប់ហើយ។

**ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស:** កិច្ចអភិវឌ្ឍន៍វិស័យឯកជន គឺជាគ្រឹះមួយនៃសសរគ្រឹះទាំងឡាយនៃប្រតិបត្តិការរបស់ ADB នៅក្នុងប្រទេសកម្ពុជា។ កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ គឺជាគោលដៅអាទិភាពមួយ ហើយវិស័យនេះ គឺជាវិស័យមួយដែលនៅក្នុងនោះ ADB បានដើរតួនាទីនាំមុខគេរហូតមកទល់បច្ចុប្បន្ននេះ។

ខ. **គោលដៅ និង គោលបំណង:** ផ្អែកលើសមិទ្ធិផលសម្រេចបានក្រោមអនុកម្មវិធីទី ១ និង ទី ២ នៃ FSPL I អនុកម្មវិធីទី ៣ នឹងពង្រឹងការអនុវត្តន៍ផែនការវិស័យហិរញ្ញវត្ថុដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងដែលត្រូវបានអនុម័ត និងផ្តួចផ្តើមការអនុវត្តន៍វិស័យជាក់លាក់ទាំងឡាយនៃតំណាក់កាលបន្ទាប់នៃកំណែទម្រង់វិស័យហិរញ្ញវត្ថុនៅកម្ពុជា។ គោលដៅសំដៅគាំទ្រកិច្ចអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ និងប្រកបដោយប្រសិទ្ធិភាពមួយដែលនឹងលើកកំពស់ប្រសិទ្ធិភាពនៅក្នុងការគៀងគរធនធាន និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព។

គ. **សមាសភាគ និង សមិទ្ធិផល:** ផ្អែកលើសមិទ្ធិផលសម្រេចបានក្រោមអនុកម្មវិធីទី ១ និង ទី ២ និងឈរលើផែនការវិស័យហិរញ្ញវត្ថុដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនិងដែលត្រូវបានអនុម័ត សមាសភាគចំបងទាំងឡាយនៃអនុកម្មវិធីទី ៣ រួមមាន ទី(១) ពង្រឹងតួនាទីត្រួតពិនិត្យប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា (NBC) និង ការពង្រីកការកសាងសមត្ថភាពត្រួតពិនិត្យទៅក្នុងវិស័យថ្មីៗ (ដែលរួមមាន (ក) ការគាំទ្របន្ថែមចំពោះការអនុវត្តន៍ប្លង់គណនី និង ស្តង់ដារផ្តល់ព័ត៌មាន (ខ) ការណែនាំបុគ្គលិក NBC នៅក្នុងការធ្វើអធិការកិច្ចនៅនឹងកន្លែងឱ្យបានពេញលេញ (គ) ការពង្រីកការកសាងសមត្ថភាពត្រួតពិនិត្យទៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ភតិសន្យា និង គ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត) ទី(២) ពង្រឹងការអនុវត្តន៍ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ និង គាំទ្រកិច្ចអភិវឌ្ឍន៍ច្បាប់និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល និង ប្រព័ន្ធតុលាការមួយដែលសមស្របសម្រាប់វិស័យនេះ ទី(៣) គាំទ្រដកវិនិយោគរបស់រដ្ឋាភិបាលចេញពីអាជីវកម្មធានារ៉ាប់រង និង ពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ប្រតិបត្តិការងារធានារ៉ាប់រងដ៏រឹងមាំ (៤) ពង្រឹងទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និង (៥) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ រួមទាំងកិច្ចអភិវឌ្ឍន៍បន្ថែមទៀតនូវវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម តុលាការពាណិជ្ជកម្មនៅក្នុងប្រព័ន្ធតុលាការ ការផ្លាស់ប្តូរព័ត៌មានឥណទាន ។ល។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** ក្រោយពេលបញ្ចប់អនុកម្មវិធីទី ៣ គេរំពឹងថា ទី(១) កិច្ចអភិវឌ្ឍន៍វិស័យធនាគារ: ការត្រួតពិនិត្យប្រុងប្រយ័ត្ននៃធនាគារជាតិនៃកម្ពុជា នឹងត្រូវបានពង្រឹងជំនាញរបស់បុគ្គលិកធនាគារនឹងត្រូវ

| |
|---|
| បានលើកកំពស់តាមរយៈការបណ្ដុះបណ្ដាលដែលត្រូវបានផ្ដល់ជូនដោយវិទ្យាស្ថានធនាគារឯកជន ហើយទំនុកចិត្តលើវិស័យធនាគារនឹងត្រូវបានកែលំអយ៉ាងច្រើន ទី(២) កិច្ចអភិវឌ្ឍន៍វិស័យធានារ៉ាប់រងៈ បទប្បញ្ញត្តិនឹងត្រូវបានពង្រឹងសមត្ថភាពនៃអ្នកគ្រប់គ្រងការងារធានារ៉ាប់រងនឹងត្រូវបានលើកកំពស់ ហើយក្រុមហ៊ុនធានារ៉ាប់រងរដ្ឋនឹងត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ និង ត្រូវបានដកវិនិយោគចេញ ទី(៣) កិច្ចអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុៈ ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់ នឹងត្រូវបានអនុម័តនិងអនុវត្ត ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មត្រូវបានអនុម័តនិងអនុវត្ត ហើយសេចក្តីព្រាងច្បាប់មូលប័ត្រនិងទីផ្សារហ៊ុននឹងត្រូវបានដាក់ជូនរដ្ឋសភាជាតិ និង ទី(៤) កិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធៈ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានឹងត្រូវបានអនុម័ត ហើយប្រព័ន្ធចុះបញ្ជីអេឡិកត្រូនិកជាសាធារណៈសម្រាប់ប្រតិបត្តិការដែលមានកិច្ចធានានឹងត្រូវបានបង្កើតឡើង វិទ្យាស្ថានគណនេយ្យនិងសវនកម្មនឹងត្រូវបានពង្រឹង ស្តង់ដារដែលត្រូវបានឯកភាពនឹងត្រូវបានអនុម័តយ៉ាងទូលាយ គេនឹងឃើញមានការកែលំអបន្ថែមទៀតចំពោះប្រព័ន្ធតុលាការ ដើម្បីជួយដល់ការដាក់ឱ្យអនុវត្តកិច្ចសន្យា។<br><br>ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថានៈ** ផលប៉ះពាល់សង្គមកិច្ចគឺមានលក្ខណៈវិជ្ជមាន ហើយបញ្ហាបរិស្ថានគឺមានតិចបំផុត។<br><br>ច. **ផែនការផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផលៈ** ADB នឹងរក្សាការពិភាក្សាគោលនយោបាយដ៏សកម្មជាមួយភាគីពាក់ព័ន្ធវិស័យសាធារណៈនិងឯកជនទាំងអស់នៅក្នុងការរៀបចំកម្មវិធី និង ផ្សព្វផ្សាយលទ្ធផលនៃកម្មវិធី។ |
| ៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ធនាគារជាតិនៃកម្ពុជាគឺជាស្ថាប័នប្រតិបត្តិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នអនុវត្ត។ |
| ៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍ក្នុងការផ្ដើមគោលគំនិត និង កំណត់អំពីគម្រោងជំនួយៈ** ការរៀបចំគម្រោងគឺផ្អែកលើផែនការវិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០ ដែលត្រូវបានរៀបចំឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធវិស័យសាធារណៈនិងឯកជនទាំងអស់។ រាជរដ្ឋាភិបាលបានអនុម័តផែនការនេះនៅក្នុងខែសីហា ឆ្នាំ ២០០១ និង មានគម្រោងធ្វើបច្ចុប្បន្នកម្មផែនការនេះ ដោយចាប់ផ្ដើមនៅក្នុងត្រីមាសទីបួននៃឆ្នាំ ២០០៤។ ព័ត៌មានពិស្តារនៃអនុកម្មវិធីទី ៣ នឹងត្រូវបានកែលំអបន្ថែមទៀតក្រោយពីមានការវាយតម្លៃលើវឌ្ឍនភាពមកទល់បច្ចុប្បន្ននេះ និងការពិភាក្សាជាមួយស្ថាប័នរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធវិស័យឯកជន។ ដោយហេតុនេះ គម្រោងការណ៍ចុងក្រោយនៃកម្មអនុវិធីនេះ នឹងឆ្លុះបញ្ចាំងការប្រែប្រួលនៅក្នុងបរិយាកាសសង្គម នយោបាយ និង សេដ្ឋកិច្ច នឹងផ្អែកលើវឌ្ឍនភាពដែលស្ថាប័ន រដ្ឋាភិបាល និង ភាគីពាក់ព័ន្ធវិស័យឯកជនសម្រេចបានក្រោមអនុកម្មវិធីមុនទាំងពីរ។ |

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៏:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៤

ខ. កាលបរិច្ឆេទរំពឹងទុកនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៥

មិនមែនជាកម្ចីឥណទាន (សំរាប់ការត្រៀមរៀបចំគម្រោង):

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន: ២០០៥-២០០៦

មិនមែនកម្ចីឥណទាន:

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៏អាស៊ី: ១០ លានដុល្លារ

☐ ផ្សេងទៀត:

ADB = ធនាគារអភិវឌ្ឍន៏អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស IMF = មូលនិធិរូបិយវត្ថុអន្តរជាតិ RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៥.៧: អគារសម្រាប់ក្រុមប្រឹក្សាឃុំ - តំណាក់កាលទី ២
## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☒ ប្រភេទកម្ចីឥណទាន
  - ☒ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☒ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ច្បាប់ និង ការគ្រប់គ្រងវិស័យសាធារណៈ

អនុវិស័យ:

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់

☒ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: អភិបាលកិច្ចសាធារណៈ

**៣. វិសាលភាពគ្របដណ្ដប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកអភិបាលកិច្ច ហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** S. Nicoll អ្នកឯកទេស NGO ជាន់ខ្ពស់

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** កំណែទម្រង់រដ្ឋបាលសាធារណៈនិងអភិបាលកិច្ចមូលដ្ឋានគឺជាវិស័យគន្លឹះនៃការគាំទ្ររបស់ ADB ក្រោមកម្មវិធីនិងយុទ្ធសាស្ត្រប្រចាំប្រទេសបច្ចុប្បន្ន (CSP)និង សេចក្តីព្រាង CSP ឆ្នាំ ២០០៥-២០០៩។ ADB បានគាំទ្រកិច្ចអភិវឌ្ឍន៍អភិបាលកិច្ចមូលដ្ឋានតាមរយៈគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ-សង្កាត់ (CCDP)។ គោលបំណងនៃ CCDP គឺការកាត់បន្ថយភាពក្រីក្រកាន់តែល្អតាមរយៈអភិបាលកិច្ចកាន់តែមានលក្ខណៈចូលរួម តម្លាភាព និង គណនេយ្យភាពនៅកម្រិតឃុំ-សង្កាត់នៅក្នុងទូទាំងប្រទេសកម្ពុជា។ សមាសភាគទី ១ នៃ CCDP មានបំណងបង្កើតអគារឃុំចំនួន ៤២០ នៅក្នុងខេត្តជនបទចំនួន ២០ នៅក្នុងទូទាំងប្រទេស។

ក្រុមប្រឹក្សាឃុំដែលត្រូវបានបោះឆ្នោតជ្រើសរើសលើកទីមួយនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០២ នឹងដើរតួនាទីដ៏សកម្មនៅក្នុងការជម្រុញលទ្ធិប្រជាធិបតេយ្យ និង គឺជាអាជ្ញាធរមូលដ្ឋានសម្រាប់ការធ្វើផែនការ និង ការអនុវត្តកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឃុំ។ លើសពីនេះទៀត ឃុំនិងរដ្ឋបាលគឺទទួលខុសត្រូវលើការផ្តល់សេវាកម្មសង្គម រួមមានការចុះបញ្ជីពលរដ្ឋ។ បច្ចុប្បន្ននេះ ឃុំជាច្រើនមិនមានការិយាល័យ ឬ មានទីស្នាក់ការបណ្តោះអាសន្នដែលទ្រុឌទ្រោម។ គោលបំណងរយៈពេលមធ្យមគឺដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាឃុំទាំងអស់មានអគារ និងសំភារៈជាមូលដ្ឋានដែលចាំបាច់ដើម្បីដំណើរការប្រកបដោយប្រសិទ្ធិភាព។

រចនាសម្ព័ន្ធ ដំណើរការ និង នីតិវិធីសម្រាប់ការកំណត់បណ្ដាឃុំដែលមានលក្ខណៈសមស្របសម្រាប់ការទទួលអគារ ការទទួលការអនុម័តចាំបាច់ពីរដ្ឋាភិបាល ការដាក់ដេញថ្លៃកិច្ចសន្យាសាងសង់ និង ការឃ្លាំមើលនិងការត្រួតពិនិត្យអ្នក-ម៉ៅការ ត្រូវបានបង្កើតឡើងយ៉ាងល្អក្រោម CCDP ។ ដំណើរការនិងនីតិវិធីគន្លឹះទាំងឡាយ រួមមាន (១) កិច្ចព្រម-ព្រៀងលើវិធីសាស្ត្រអនុវត្តន៍គម្រោងដែលគោរពតាមការណែនាំនិងបទដ្ឋានកំណត់របស់រដ្ឋាភិបាលសម្រាប់ការធ្វើលទ្ធកម្មដោយក្រុមប្រឹក្សាឃុំ (២) ការធ្វើអង្កេតលើការវាយតម្លៃតម្រូវការអគារឃុំ វិធីផ្ដល់ពិន្ទុផ្លូវការសម្រាប់ការជ្រើសរើសឃុំ និង ការបង្កើតបញ្ជីអាទិភាពឃុំ (៣) ទស្សនាទានប្លង់ជាស្តង់ដារ និង ការគូសប្លង់ស្ថាបត្យកម្មនិងរចនា-សម្ព័ន្ធលំអិតសម្រាប់គម្រូស្តង់ដារចំនួនបីដែលផ្អែកលើប្លង់ប្រពៃណីខ្មែរដែលគប្បីឆ្លុះបញ្ចាំងមោទនភាពមូលដ្ឋាន (៤) ការប៉ាន់ស្មានតម្លៃលំអិតសម្រាប់ប្លង់ជាស្តង់ដារទាំងបី និង (៥) វិធីលទ្ធកម្មជាស្តង់ដារកំណត់ និង ឯកសារពាក់ព័ន្ធសម្រាប់ការងារសាងសង់ដោយក្រុមប្រឹក្សាឃុំ ។

បច្ចុប្បន្ននេះ ADB គឺជាអ្នកផ្ដល់ជំនួយតែមួយគត់ដែលផ្ដល់ជំនួយដ៏ច្រើនដល់រាជរដ្ឋាភិបាលក្នុងការសាងសង់អគារនិងការិយាល័យឃុំដែលចាំបាច់សម្រាប់បំពេញមុខងារ ។ គម្រោងការងារសាងសង់តូចៗទាំងនេះបានផ្ដល់ឱកាសដ៏ប្រសើរសម្រាប់ឱ្យក្រុមប្រឹក្សាឃុំប្រើប្រាស់ជំនាញនៃភាពជាអ្នកដឹកនាំ ការត្រួតពិនិត្យ និង ការឃ្លាំមើលការងារអភិវឌ្ឍន៍របស់ខ្លួននៅក្នុងការគ្រប់គ្រងអ្នកម៉ៅការដែលទទួលខុសត្រូវលើការសាងសង់ ។ ការរៀនសូត្រនេះត្រូវបានលើកស្ទួយដោយបរិស្ថានគាំទ្រមួយដែលផ្ដល់ឱ្យដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និង អ្នកពិគ្រោះការងារជាតិក្រោម CCDP ។ សមាជិកនិងបុគ្គលិកក្រុមប្រឹក្សាឃុំបានអនុវត្តន៍យ៉ាងល្អនៅក្នុងការបំពេញមុខងារទាំងនេះ ។

ក្រោយពេលដែលបណ្ដាអគារឃុំចាំបាច់ត្រូវបានបង្កើត នៅពេលនោះ ក្រុមប្រឹក្សាឃុំអាចយកចិត្តទុកដាក់លើមុខងាររដ្ឋបាលគន្លឹះទាំងឡាយដើម្បីធ្វើឱ្យមានដំណើរការដ៏រលូននៃប្រតិបត្តិការក្រុមប្រឹក្សា ។ ជំនាញលើការគ្រប់គ្រងការិយា-ល័យនឹងមានសារៈសំខាន់ដើម្បីការពារទ្រព្យសម្បត្តិឃុំ ដូចជាសំភារៈនិងគ្រឿងសង្ហារឹម ការត្រួតពិនិត្យសារពើភ័ណ្ឌនៃសំភារៈ និង ការការពារឯកសារផ្លូវការទាំងឡាយ ដូចជាឯកសារចុះបញ្ជីពលរដ្ឋជាដើម ។ ការរក្សានិងការទុកដាក់ឯកសារប្រកបដោយប្រសិទ្ធិភាព នឹងមានសារៈសំខាន់ដើម្បីអនុញ្ញាតឱ្យឃុំអាចផ្ដល់សេវាកម្មយ៉ាងមានប្រសិទ្ធិភាពជូនដល់សមាជិកសហគមន៍ ។ ក្រុមប្រឹក្សាឃុំនឹងមានការទទួលខុសត្រូវមួយលើការធ្វើឱ្យអគារក្រុមប្រឹក្សាឃុំមិនគ្រាន់តែក្លាយទៅជាកន្លែងធ្វើការងារសម្រាប់សមាជិកក្រុមប្រឹក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏គឺជាកន្លែងជួបប្រជុំផងដែរសម្រាប់សមាជិក-សហគមន៍សម្រាប់សកម្មភាពសាធារណៈ ។

ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាឃុំទាំងអស់មានអគារជាមូលដ្ឋានដែលចាំបាច់ដើម្បីបំពេញមុខងាររបស់ខ្លួន មានសំណើសុំឱ្យមានការអនុវត្តន៍តំណាក់កាលទីពីរនៃអគារក្រុមប្រឹក្សាឃុំដើម្បីបង្ហើយដំណើរការនៃការសាងសង់អគារជាមូលដ្ឋាននៅតាមបណ្ដាឃុំនៅក្នុងទូទាំងប្រទេស ។ ក៏មានសំណើផងដែរសុំឱ្យផ្ដល់ការគាំទ្រចំពោះការកសាងសមត្ថភាពនៃ

ក្រុមប្រឹក្សាឃុំដើម្បីថែរក្សា និង គ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពនូវទ្រព្យសម្បត្តិ សារពើភ័ណ្ឌ និង ឯកសាររបស់ឃុំ ។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃគម្រោងគឺដើម្បីគាំទ្រក្រុមប្រឹក្សាឃុំដើម្បីគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពនូវកិច្ចអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៃឃុំរបស់ខ្លួន។ គោលបំណងនៃគម្រោង គឺដើម្បីផ្តល់ជូនក្រុមប្រឹក្សាឃុំនូវអគារការងារដើម្បីបំពេញមុខងារយ៉ាងមានប្រសិទ្ធិភាព ។

គ. **សមាសភាគ និង សមិទ្ធិផល:** ទិន្នផលរបស់គម្រោង រួមមាន (១) សាងសង់អគារក្រុមប្រឹក្សាឃុំរហូតដល់ចំនួន ១.១៤០ (២) ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំក្នុងការធ្វើផែនការ គ្រប់គ្រង និង ត្រួតពិនិត្យគម្រោងសាងសង់ និង (៣) ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សានិងស្មៀនឃុំនៅក្នុងការគ្រប់គ្រងការិយាល័យ ការគ្រប់គ្រងទ្រព្យសម្បត្តិ ការថែរក្សា និង ការទុកដាក់ឯកសារ ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** លទ្ធផលរបស់គម្រោងនឹងគឺជា (១) ក្រុមប្រឹក្សាឃុំទាំងអស់មានអគារដំណើរការដែលមានសំភារៈគ្រប់គ្រាន់ (២) សមាជិកក្រុមប្រឹក្សាឃុំមានសមត្ថភាពគ្រប់គ្រងគម្រោងសាងសង់តូចតាច និង (៣) ក្រុមប្រឹក្សាឃុំគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពនូវទ្រព្យសម្បត្តិនៃអគារឃុំសម្រាប់សហគមន៍ ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** ក្រុមប្រឹក្សាឃុំទាំងអស់នឹងចាំបាច់ត្រូវចុះបញ្ជីដីធ្លីដែលអគារឃុំត្រូវបានសាងសង់នៅលើ ជាមួយនឹងការិយាល័យចុះបញ្ជីដីធ្លី ។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** លទ្ធផលពី CCDP នឹងជូនព័ត៌មានដល់ការរៀបចំ CCDP - គម្រោងសាងសង់អគារ តំណាក់កាលទី ២ និង នឹងត្រូវបានផ្សព្វផ្សាយនៅក្នុងទូទាំងប្រទេស។ មេរៀនដែលបានទទួលពីសមាសភាគកសាងសមត្ថភាពក្រោម CCDP នឹងរួមចំណែកដល់ការធ្វើគម្រោងការណ៍សកម្មភាពកសាងសមត្ថភាពក្រោមគម្រោងសាងសង់អគារក្រុមប្រឹក្សាឃុំ តំណាក់កាលទី ២ ។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ក្រសួងមហាផ្ទៃគឺជាស្ថាប័នប្រតិបត្តិដែលត្រូវបានស្នើឡើង។ ស្ថាប័នអនុវត្តនឹងគឺជាក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងទូទាំងប្រទេស ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយ:** ក្នុងអំឡុងពេលនៃបេសកកម្មពិនិត្យវាយតម្លៃ CCDP របស់ ADB នៅក្នុងខែ ឧសភា ឆ្នាំ ២០០៤ ក្រសួងមហាផ្ទៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានស្នើសុំឱ្យ ADB ពិចារណាលើការជួយគាំទ្រតំណាក់កាលទីពីរនៃការផ្តល់អគារក្រុមប្រឹក្សាឃុំ ។

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៏:**

ក. ឆ្នាំដែលត្រូវបានរាប់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៤

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ២០០៦

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): ២០០៥

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន : ២០០៦-២០០៨: ៣០ ខែ

មិនមែនជាកម្ចីឥណទាន : ២០០៥-២០០៦: ៩ ខែ

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស: ៤០០.០០០ ដុល្លារ

☐ ផ្សេងទៀត:

ប្រសិនបើចាំបាច់ត្រូវមានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពសុំ: មិនទាន់សម្រេច

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៥.៨: មណ្ឌលដែល បណ្តុះបណ្តាលស្ត្រី អោយមានសមត្ថភាព និង តួនាទីសំខាន់ក្នុងសង្គម (WEC)

## ឯកសារគោលគំនិត

កាលបរិច្ឆេទ: ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☒ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ពហុវិស័យ (អប់រំ សុខាភិបាល និង ឧស្សាហកម្មនិងពាណិជ្ជកម្ម)

អនុវិស័យ: ពហុវិស័យ (ការអប់រំបច្ចេកទេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង កិច្ចអភិវឌ្ឍន៍ជំនាញ សេវាកម្មសុខាភិបាលនិងសេវាកម្មសង្គមដទៃទៀត និង សហគ្រាសខ្នាតតូចនិងមធ្យម)

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់

☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: សមធមិយេនឌ័រលើសមត្ថភាព និង សមធមិយេនឌ័រលើការផ្តល់អំណាចនិងសិទ្ធិ

**៣. វិសាលភាពគ្របដណ្តប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកវិស័យសង្គមកិច្ច/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** មិនទាន់សម្រេច

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** ADB ទទួលស្គាល់ថា បញ្ហាដែលពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍន៍ប្រទេសកម្ពុជា មានការទាក់ទិនជាមួយតួនាទីរបស់ស្ត្រីយ៉ាងសំខាន់។ ទោះបីជាស្ត្រីបានរួមចំណែកយ៉ាងសកម្មក៏ដោយ ក៏ពួកគេមិនបានទទួលអត្ថប្រយោជន៍ ពីកំណើនសេដ្ឋកិច្ចនិងកិច្ចអភិវឌ្ឍន៍ ដូចជាបុរសនោះទេ។ អនក្ខរភាពខ្ពស់ និង កម្រិតវប្បធម៌ទាប បានរារាំងកាលានុវត្តភាពសេដ្ឋកិច្ចរបស់ស្ត្រី និង គៀបសង្កត់លើសុខុមាលភាពរបស់ស្ត្រី។ ដើម្បីជម្រុញកំណើនសេដ្ឋកិច្ចលើវិស័យជាច្រើននិងកាត់បន្ថយភាពក្រីក្រ ADB នឹងគាំទ្រដល់ការលើកកំពស់ផលិតភាពនិងសមត្ថភាពរកប្រាក់ចំណូលរបស់ស្ត្រី តាមរយៈការវិនិយោគនៅក្នុងវិស័យកសិកម្ម និងធនធានធម្មជាតិ នៅក្នុងការកែប្រែជីវភាពនៅជនបទអោយបានល្អប្រសើរ និងនៅក្នុងសហគ្រាសខ្នាតតូចនិងមធ្យម (SME)។ ជាការពិតណាស់ដែលថា កំរិតវប្បធម៌របស់ស្ត្រីនិងការមានតួនាទីសំខាន់ក្នុងសង្គមរបស់ស្ត្រី គឺមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងរបបហូបចុករបស់ស្ត្រីកាន់តែបានល្អ ការពន្យារកំណើត កុមារកាន់តែរៀនបានច្រើនថ្នាក់ និងមានសុខភាពកាន់តែប្រសើរ។ ADB នឹងគាំទ្រដល់កិច្ចប្រឹងប្រែងទាំងឡាយ ដើម្បីរៀបចំជាវិធានការសមស្របជាក់ស្តែងឆ្ពោះទៅកាន់សមធមិយេនឌ័រ។

ខ. **គោលដៅ និង គោលបំណង:** កម្មវិធីមណ្ឌលដើម្បី ស្ត្រីមានតួនាទីដ៏សំខាន់ក្នុងសង្គម នឹងបង្កើតយន្តការមួយដើម្បីពង្រីក

លទ្ធភាពទទួលសេវាកម្មទាំងឡាយ សំដៅគាំទ្រពង្រឹងអោយស្ត្រីឈានទៅមានសមត្ថភាព និងតួនាទីសំខាន់ក្នុងវិស័យសេដ្ឋកិច្ចសង្គម។ គម្រោងនេះ នឹងរួមចំណែកដល់ការសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលឆ្លើយតបនឹងយេនឌ័រ ដែលរួមមានចំណុចដៅផ្នែកជំរុញអក្ខរកម្ម និង ធ្វើអោយស្ត្រីបានទទួលការងារមានប្រាក់កំរៃដូចជាបុរស ក៏ដូចជាចំណុចដៅសម្រាប់ការកាត់បន្ថយភាពក្រីក្រផងដែរ។

គ. **សមាសភាគ និង សមិទ្ធិផល:** (១) ជួសជុលកែលំអមណ្ឌលស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ (WID) ដែលមានស្រាប់ ចំនួនពីរកន្លែង ដើម្បីអាចទទួលនូវសេវាកម្មបន្ថែមនានា ដែលនឹងត្រូវបានផ្តល់តាមរយៈមណ្ឌលទាំងពីរនេះ (២) ធ្វើការវិភាគសិក្សានិងបង្កើតគណៈកម្មាធិការផ្តល់យោបល់នៅមូលដ្ឋាន ដើម្បីជួយកំណត់អាទិភាពអំពីសេវាកម្មដែលមណ្ឌលទាំងនេះ នឹងរៀបចំឡើង (៣) រៀបចំផែនការស្តីពីការគ្រប់គ្រងមណ្ឌលនិងបុគ្គលិកសម្រាប់មណ្ឌលទាំងនេះ (៤) រកអោយឃើញភាគីជាដៃគូដែលមានសេវាតបឆ្លើយនឹងតម្រូវការរបស់មណ្ឌល និង ចុះកិច្ចសន្យាជាមួយគេ ក្នុងការផ្តល់សេវាកម្មរបស់គេនៅក្នុងមណ្ឌលទាំងនេះ (៥) ពង្រឹងសមត្ថភាពនៃបុគ្គលិក របស់មណ្ឌលដើម្បីស្ត្រីមានតួនាទីសំខាន់ក្នុងសង្គម (WEC) ដើម្បីអោយការងារគ្រប់គ្រងនិងផ្តល់សេវាកម្មដល់ស្ត្រីដំណើរការបានល្អ (៦) ពង្រឹងសមត្ថភាពនៃបុគ្គលិករបស់ក្រសួងកិច្ចការនារី (MoWA) ក្នុងការផ្តល់មតិណែនាំនិងគាំទ្រជួយដល់ការងាររបស់មណ្ឌល (៧) រៀបចំជាយុទ្ធសាស្ត្រមួយដើម្បីធានាចីរភាពរយៈពេលវែងនៃមណ្ឌលទាំងនេះ និង (៨) រៀបចំជាយុទ្ធសាស្ត្រ សំដៅប្រែក្លាយមណ្ឌលរបស់ស្ត្រីដែលមានតែជំនាញកាត់ដេរត្បាញរវៃ (WID) នៅតាមខេត្តផ្សេងទៀត អោយទៅជាមណ្ឌលដែលបណ្តុះបណ្តាលស្ត្រី អោយមានសមត្ថភាព និង តួនាទីសំខាន់ក្នុងសង្គម (WEC) ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** មណ្ឌល WID ដែលមានស្រាប់ទាំងពីរនេះ នឹងត្រូវបានប្រែក្លាយទៅជាមណ្ឌលដែលបណ្តុះបណ្តាលស្ត្រីអោយមានសមត្ថភាពនិងតួនាទីសំខាន់ក្នុងសង្គម (WEC) ។ មណ្ឌលទាំងនេះនឹងផ្តល់នូវកញ្ចប់ សេវាកម្មមួយដែលមានជំនាញច្រើនបែបស្របតាមតំរូវការទីផ្សារ ដើម្បីលើកកំពស់សមត្ថភាពរបស់ស្ត្រីអោយមាន តួនាទីផ្នែកសេដ្ឋកិច្ចសង្គម ដែលរួមមាន (១) ការបណ្តុះបណ្តាលនិងការគាំទ្រ ដើម្បីអោយស្ត្រីមានតួនាទីសំខាន់ ផ្នែកវប្បធម៌សង្គមកិច្ច (ឧទាហរណ៍ដូចជា ជួយអោយស្ត្រីចេះអាននិងសរសេរត្រឹមត្រូវមានចំណេះដឹងដែលពាក់ព័ន្ធនឹងការចិញ្ចឹមជីវិត មានការអប់រំអំពីសុខភាពបន្តពូជ មានការយល់ដឹងអំពីច្បាប់សំខាន់ៗ ចេះរៀបចំជាក្រុមសំរាប់ជួយគាំទ្រគ្នាទៅវិញទៅមកជាដើម) (២) កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស (ឧទាហរណ៍ ដូចជាការបណ្តុះបណ្តាលជំនាញ ដែលតបឆ្លើយទៅនឹងតំរូវការរបស់ទីផ្សារ រៀបចំសាកល្បងជាក្រុមបណ្តុះបណ្តាលចល័ត ជាដើម) (៣) ការបណ្តុះបណ្តាល និង គាំទ្រស្ត្រីអោយចេះចាត់ចែងធ្វើមីក្រូសហគ្រាស (ដោយផ្តល់នូវការបណ្តុះបណ្តាលអំពីជំនាញគ្រប់គ្រង សម្រួលអោយស្ត្រីអាចទទួលបាន នូវការផ្តល់ប្រឹក្សាផ្នែកធ្វើអាជីវកម្ម នូវការខ្ចីទុនរកស៊ី នូវពត៌មានអំពីទីផ្សារ អំពីបច្ចេកវិទ្យាថ្មី វត្ថុធាតុដើម ។ល។ និង ការរួមគ្នាបង្កើតជាសមាគមន៍) និង (៤) មណ្ឌលមានអគារសំភារៈសំរាប់ការប្រើប្រាស់ជារួម និង/ឬអង្គភាពបណ្តុះបណ្តាល

អាជីវកម្មដែលនឹងណែនាំស្ត្រីអំពីវិធីបំពេញក្រដាសស្នាមដើម្បីទទួលការផ្តល់អាជ្ញាប័ណ្ណ សំរាប់សម្រួលដល់ការចាប់ផ្តើមអាជីវកម្ម ព្រមទាំងមានតួនាទីជាប្រភពនៃការផ្តល់ពត៌មាន និង ការគាំទ្រចំពោះកិច្ចអភិវឌ្ឍន៍ផលិតផល ការរចនារៀបរៀងជាពុម្ព ការផ្គត់ផ្គង់សំភារៈ និង ការរកទីផ្សារដើម្បីលក់សំភារៈជាដើម ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថានៈ** គ្មាន

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផលៈ** តាមរយៈសិក្ខាសាលាជាមួយភាគីដែលពាក់ព័ន្ធទាំងអស់ ។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ក្រសួងកិច្ចការនារី

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយៈ**
រាជរដ្ឋាភិបាលស្នើសុំជំនួយសម្រាប់គម្រោងសាកល្បងនេះ ដើម្បីបំពេញកង្វះដ៏សំខាន់ផ្នែកខាងលើនេះ នៅក្នុងសេវាកម្មដែលកំពុងដំណើរការ សំដៅគាំទ្រពង្រឹងអោយស្ត្រីឈានទៅមានសមត្ថភាពនិងតួនាទីសំខាន់ក្នុងវិស័យសេដ្ឋកិច្ចសង្គម នៅប្រទេសកម្ពុជា ។ កម្មវិធីនេះនឹងប្រមូលលទ្ធផលដែលមានកន្លងមក ព្រមទាំង បន្ត កសាងលើមេរៀនបទពិសោធន៍ ដែលបានទទួលពីសកម្មភាពនានា ដែលក្រសួងកិច្ចការនារីបានអនុវត្តក្នុងរយៈពេល១០ឆ្នាំ កន្លងមកនេះ ។ មានការគិតគូរ អំពីកិច្ចសហការ ជាមួយគម្រោងនិងកម្មវិធីទៃទៀតរបស់រដ្ឋាភិបាល របស់ស្ថាប័នផ្តល់មូលនិធិបរទេសនានា របស់អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ត្រូវបានទទួលការពិចារណាយ៉ាងពេញលេញ នៅពេលដែលទស្សនាទានគម្រោងត្រូវបានរៀបចំ ។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍ៈ**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: ឆ្នាំ ២០០៥

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទានៈ
មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង)ៈ
មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង)ៈ ត្រីមាសទីបួន ឆ្នាំ ២០០៥

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន :
មិនមែនជាកម្ចីឥណទាន : ២០០៦-២០០៨

| |
|---|
| **១០. ផែនការហិរញ្ញប្បទាន**<br><br>ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ថវិការដ្ឋបាលរបស់ ADB:<br>☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស:<br>☒ ផ្សេងទៀត: ហិរញ្ញប្បទានរួម / ធនធានមូលនិធិក្នុងអាណត្តិព្យាបាលភាព<br><br>ប្រសិនបើចាំបាច់ត្រូវមានហិរញ្ញប្បទានរួម ចូរបង្ហាញចំនួននិងប្រភពសុំ: ១,៥ លានដុល្លារ ប្រភពមិនទាន់សម្រេច |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្រ្តនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្រ្តនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៥.៩: អន្តេវាសិកដ្ឋានសម្រាប់សិស្សនារីនៅសាលាមធ្យមសិក្សា
## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☐ ប្រភេទកម្ចីឥណទាន
  - ☐ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☐ សំរាប់ត្រៀមរៀបចំគម្រោង
  - ☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☒ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: អប់រំ

អនុវិស័យ: ការអប់រំមូលដ្ឋាន

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ:

☐ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់

☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

ប្រធានបទរង: សមធមិយេនដ័រនៅក្នុងការទទួលបាននូវឱកាស និងការអភិវឌ្ឍន៍ធនធានមនុស្ស

**៣. វិសាលភាពគ្របដណ្ដប់**

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកវិស័យសង្គមកិច្ច/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** នឹងត្រូវកំណត់

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សាវតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** ADB ទទួលស្គាល់ថាចំណោទនៃការអភិវឌ្ឍន៍កម្ពុជាមានទិដ្ឋភាពយេនដ័រដ៏សំខាន់មួយ។ ទោះបីជាស្ត្រីបានរួមចំណែកយ៉ាងសកម្មក៏ដោយ ក៏ពួកគេមិនបានទទួលអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍន៍ ដូចជាបុរសនោះទេ។ អនក្ខរភាពខ្ពស់ និង កម្រិតវប្បធម៌ទាបរារាំងកាលានុវត្តភាពសេដ្ឋកិច្ចរបស់ស្ត្រី និង កៀបសង្កត់លើសុខុមាលភាពរបស់ស្ត្រី។ គេឃើញច្បាស់ថាការអប់រំរបស់ស្ត្រី និងការផ្ដល់អំណាចដល់ស្ត្រី គឺមានទំនាក់ទំនងជាវិជ្ជមាន ជាមួយនឹងរបបហូបចុករបស់ស្ត្រីកាន់តែប្រសើរ ការពន្យារកំណើត និងការសិក្សាអប់រំ និងមានសុខភាពកាន់តែប្រសើររបស់កុមារ។ គេឃើញមានកុមារីចំនួនប្រហែល ៦៣ នាក់ សំរាប់កុមារចំនួន ១០០ នាក់នៅក្នុងកំរិតមធ្យមសិក្សាបឋមភូមិ និត មានកុមារីតិចជាង ៥០ នាក់ សំរាប់កុមារាចំនួន ១០០ នាក់នៅក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ និង ឧត្តមសិក្សា។ អត្រាបោះបង់ការសិក្សាក្នុងចំណោមកុមារី គឺខ្ពស់ជាងកុមារានៅក្នុងគ្រប់កម្រិត ជាពិសេសនៅតាមតំបន់ជនបទ។ ADB នឹងគាំទ្រដល់កិច្ចប្រឹងប្រែងទាំងឡាយ ដើម្បីផ្ដល់ជាវិធានការជាក់ស្ដែងនានា ឆ្ពោះ ទៅកាន់សមធមិយេនឌ័រ។

ខ. **គោលដៅ និង គោលបំណង:** គម្រោងនេះនឹងបង្កើតជាគំរូមួយ សម្រាប់ការគ្រប់គ្រងដោយផ្អែកលើសហគមន៍ នូវអន្តេវាសិកដ្ឋានសម្រាប់សិស្សនារីដែលរៀននៅសាលាមធ្យមសិក្សា។ គម្រោងនេះ នឹងរួមចំណែក ដល់ការសម្រេចអោយបាននូវចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា សំដៅបង្កើនការចូលរៀនរបស់ក្មេងស្រីនៅសាលាមធ្យមសិក្សា និង កាត់បន្ថយគម្លាតយេនឌ័រនៅក្នុងកំរិតមធ្យមសិក្សា។

គ. **សមាសភាគ និង សមិទ្ធិផលៈ** (១) សាងសង់អន្តេវាសិកដ្ឋានសម្រាប់កុមារីនៅទីកន្លែងដែលបានជ្រើសរើសចំនួនបី ជាកម្មវិធីសាកល្បងមួយ (២) បង្កើតប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើសហគមន៍ ដោយធ្វើការងារក្នុងភាពជាដៃគូរ នៅក្នុងមូលដ្ឋាន (ឧទាហរណ៍ ដូចជា NGO យាយជី អង្គការសហគមន៍) (៣) បណ្តុះបណ្តាលអ្នកគ្រប់គ្រង និង អ្នកគ្រូក្នុងមូលដ្ឋានដែលនឹងបានទទួលប្រាក់បៀវត្សរ៍បន្ថែម ដើម្បីទូទាត់ជូនពួកគេសំរាប់ការទទួលខុសត្រូវបន្ថែមរបស់ពួកគេ និង (៤) បង្កើតជាយុទ្ធសាស្ត្រមួយ ដើម្បីធានាអោយបាននូវចីរភាពរយៈពេលវែងនៃអន្តេវាសិកដ្ឋាន។ សកម្មភាពទាំងឡាយនឹងត្រូវបានអនុវត្តក្នុងរយៈពេលបីឆ្នាំ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបានៈ** កាត់បន្ថយគម្លាតយេនឌ័រនៅកំរិតមធ្យមសិក្សា។ ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺអត្រាបន្តការសិក្សាអោយបាន ១០០% (ថ្នាក់ទី ១-៩) មុនដំណាច់ឆ្នាំ ២០១៥ ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ច ឬបរិស្ថានៈ** គ្មាន

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផលៈ** ការពិគ្រោះយោបល់ និងសិក្ខាសាលាមួយចំនួន នឹងត្រូវបានរៀបចំឡើងនៅតាមខេត្តមួយចំនួន ដើម្បីជម្រុញឱ្យមានការចូលរួមដ៏សកម្មពីភាគីពាក់ព័ន្ធទាំងឡាយ រួមមកសហគមន៍ទទួលផលប្រយោជន៍ និង អង្គការសង្គមស៊ីវិល នៅក្នុងការធ្វើផែនការ និង ការអនុវត្តន៍ ជាបន្តបន្ទាប់ទៅទៀត។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ក្រសួងកិច្ចការនារី

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ឬការចាប់បដិសន្ធិជំនួយៈ** គេឃើញមានពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។ ភាពបំពេញបន្ថែមលើគម្រោង និងកម្មវិធីដទៃទៀត និង ស្ថាប័នផ្តល់មូលនិធិក្រៅប្រទេសដទៃទៀត ត្រូវបានពិចារណាយ៉ាងពេញលេញ។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍ៈ**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់ៈ ឆ្នាំ ២០០៥

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទានៈ

មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង)ៈ

មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង)ៈ ត្រីមាសទីបួន ឆ្នាំ ២០០៥

| |
|---|
| គ. អំឡុងពេលនិងរយៈពេលនៃជំនួយ<br><br>កម្ចីឥណទាន :<br>មិនមែនជាកម្ចីឥណទាន : ២00៦-២00៨ |
| **១0. ផែនការហិរញ្ញប្បទាន**<br><br>ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន<br><br>☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB<br>☐ ថវិការដ្ឋបាលរបស់ ADB:<br>☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស:<br>☒ ផ្សេងទៀត: ប្រភពសហហិរញ្ញប្បទាន / មូលនិធិរួម<br><br>ប្រសិនបើចាំបាច់ត្រូវមានសហហិរញ្ញប្បទាន ចូរបង្ហាញចំនួន និងប្រភពស៊ុំ: ៨00.000 ដុល្លារ ( ប្រភពនឹងត្រូវកំណាត់) |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។

## តារាង ក៥.១០: ការស្តារនីតិសម្បទាអាយស្ម័យយានកម្ពុជា

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

- ☒ ប្រភេទកម្ចីឥណទាន
  - ☒ ឥណទានគម្រោង
  - ☐ ឥណទានកម្មវិធីកំណែទម្រង់
  - ☐ ឥណទានវិស័យ
  - ☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ
  - ☐ ផ្សេងទៀត:
- ☒ ប្រភេទមិនមែនជាកម្ចីឥណទាន
  - ☒ សំរាប់ត្រៀមរៀបចំគម្រោង
  - ☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង
    - ☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ
    - ☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន
    - ☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ដឹកជញ្ជូន

អនុវិស័យ: អាយស្ម័យយាន

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

- ☐ អន្តរាគមន៍មានមុខព្រួញ
- ☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព ☐ ចិរភាពបរិស្ថាន

☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☒ កិច្ចសហប្រតិបត្តិការតំបន់

☒ អភិបាលកិច្ច ☒ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

**៣. វិសាលភាពគ្របដណ្តប់**

☐ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកហេដ្ឋារចនាសម្ព័ន្ធ/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** P. Broch អ្នកសេដ្ឋកិច្ចគម្រោង/ការងារដឹកជញ្ជូន

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់:** សមាគមនៃប្រទេសជាតិអាស៊ីអគ្នេយ៍ (ASEAN) បានស្នើសុំជំនួយរបស់ ADB ក្នុងការបង្កើតការផ្សារភ្ជាប់ផ្លូវរថភ្លើងរវាងប្រទេសសឹង្ហបុរីនិងគុនមីង ដែលគឺជាគម្រោងដ៏សំខាន់បំផុតមួយរបស់ ASEAN ។ យុទ្ធសាស្ត្រគម្រោងនេះគឺការស្តារឡើងវិញនិងការកែលំអជាជំហានៗនូវខ្សែផ្លូវរថភ្លើងជាតិតាមការកំណត់ជាអាទិភាពអភិវឌ្ឍន៍ជាតិ និង ការសាងសង់ការតភ្ជាប់ផ្លូវរថភ្លើងដែលមិនទាន់មាន។ ផ្នែកកណ្តាលនៃគម្រោងដ៏សំខាន់នេះគឺផ្លូវរថភ្លើងឆ្លងកាត់ប្រទេសកម្ពុជានិងវៀតណាម ដែលផ្តល់ការតភ្ជាប់ជាយុទ្ធសាស្ត្ររវាងបណ្តាញផ្លូវរថភ្លើងមានស្រាប់នៅក្នុងប្រទេសសឹង្ហបុរី ម៉ាឡេស៊ី ថៃឡង់ដ៍ និង មីយ៉ាន់ម៉ានៅទិសបស្ចឹម និងបណ្តាញផ្លូវរថភ្លើងនៅក្នុងប្រទេសវៀតណាម និង ខេត្តយ៉ន់ណាននៅបូព៌ាទិស។ កំណាត់ផ្លូវរថភ្លើងតភ្ជាប់ឆ្លងកាត់ប្រទេសកម្ពុជាក៏គឺជាផ្នែកដ៏សំខាន់មួយផងដែរនៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS) ដែលគឺជា កម្មវិធីមួយនៃកម្មវិធីដ៏សំខាន់ចំនួន ១១ ក្រោមកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់ GMS ។

ការសិក្សាយុទ្ធសាស្ត្រវិស័យដឹកជញ្ជូនកម្ពុជា (TA-3651, 2002) បានសន្និដ្ឋានថា ដោយសារផលវិបាកនៃសង្គ្រាមរាប់ឆ្នាំ ផ្លូវរថភ្លើងគឺស្ថិតនៅក្នុងស្ថានភាពទ្រុឌទ្រោម និង ចាំបាច់ត្រូវស្តារឡើងវិញមុនពេលដែលគេអាចសម្រេចបានយ៉ាងពេញលេញនូវអត្ថប្រយោជន៍ពីចរាចរតាមផ្លូវរថភ្លើង។ លទ្ធភាពចូលរួមក្នុងចរាចរផ្លូវរថភ្លើងជាប្រក្រតីនៅក្នុងតំបន់ នឹងផ្តល់អត្ថប្រយោជន៍មួយចំនួនដល់ប្រទេសកម្ពុជា: (១) ដោយកាត់បន្ថយចរាចររថយន្តផ្ទុកធ្ងន់ៗលើបណ្តាញផ្លូវ ដែលជាហេតុនាំឱ្យកាត់បន្ថយចំណាយលើការថែទាំនិងពង្រីកនាពេលអនាគត (២) ដោយកាត់បន្ថយការដឹកជញ្ជូនប្រេងឥន្ធនៈនិងទំនិញគ្រោះថ្នាក់ដទៃទៀតតាមផ្លូវ ដែលជាហេតុកាត់បន្ថយហានិភ័យចរាចរតាមផ្លូវ (៣) ដោយផ្តល់ការដឹកជញ្ជូនដែលមានតម្លៃថោកសម្រាប់ទំនិញដុំ ដូចជាស៊ីម៉ងត៍និងប្រេងឥន្ធនៈជាដើម ដែលជាហេតុកាត់បន្ថយចំណាយលើការ

នាំចូលនិងបែងចែកទំនិញចាំបាច់ទាំងនេះ និង (៤) ដោយបង្កើនសំពាធប្រកួតប្រជែងលើប្រព័ន្ធដឹកជញ្ជូនមានស្រាប់ ជាពិសេសការដឹកជញ្ជូនតាមផ្លូវ និង កំពង់ផែនៅក្រុងព្រះសីហនុ តាមរយៈការបង្កើតជម្រើសផ្លូវនិងមធ្យោបាយនៃការ-ដឹកជញ្ជូន ដែលនឹងជួយកាត់បន្ថយលទ្ធភាពកំណត់តម្លៃផ្តាច់មុខ។ ការសិក្សានេះបានបង្ហាញថា ប្រតិបត្តិការផ្លូវរថភ្លើងមានលទ្ធភាពដំណើរការបានខាងហិរញ្ញវត្ថុ ប្រសិនបើផ្លូវរថភ្លើងត្រូវបានស្តារនិងរៀបចំរចនាសម្ព័ន្ធឡើងវិញ ដោយមានការចូលរួមដ៏ពេញលេញរបស់វិស័យឯកជន។ ជាចុងក្រោយ ការសិក្សាយុទ្ធសាស្ត្រនេះបានកត់សំគាល់ថា ប្រតិបត្តិការផ្លូវរថភ្លើងមិនមានលទ្ធភាពដំណើរការបានខាងហិរញ្ញវត្ថុឡើយក្រោមកាលៈទេសៈបច្ចុប្បន្ន និង មិនអាចរកមូលនិធិដែលចាំបាច់សម្រាប់ការស្តារឡើងវិញនេះឡើយ។ វិនិយោគដ៏ច្រើនលើវិស័យផ្លូវកម្ពុជានៅក្នុងទសវត្សរ៍កន្លងមកនេះ មានគោលបំណងបង្កើតឡើងវិញនូវបណ្តាញផ្លូវសំខាន់ៗរបស់ប្រទេស ដែលនឹងត្រូវបានបង្ហើយ ប្រហែលជានៅក្នុងឆ្នាំ ២០០៦។ ការកំណត់ឡើងវិញនូវមុខព្រួញវិនិយោគវិស័យដឹកជញ្ជូន កំពុងលេចជារូបរាងរួចហើយ ដោយយកចិត្តទុក-ដាក់លើ (១) ការធ្វើឱ្យកាន់តែស៊ីជម្រៅនូវបណ្តាញផ្លូវដោយស្តារឡើងវិញនូវបណ្តាញផ្លូវលំដាប់ទីពីរ ដែលភាគច្រើនមកដល់ពេលនេះ មិនត្រូវបានគេយកចិត្តទុកដាក់ និង (២) ការបង្កើនភាពប្រកួតប្រជែងនិងភាពស័ក្តិសិទ្ធិនៃវិស័យដឹកជញ្ជូន តាមរយៈទីផ្សារដឹកជញ្ជូនដែលកាន់តែមានលក្ខណៈពិពិធកម្ម ការផ្តល់ផ្លូវនិងវិធីដឹកជញ្ជូនកាន់តែច្រើន។ កំណើនពិពិធកម្មនឹងលើកស្ទួយភាពស័ក្តិសិទ្ធិនៃវិស័យដឹកជញ្ជូនតាមវិធីពីរយ៉ាង: វានឹងបន្ថយលទ្ធភាពនៃការកំណត់តម្លៃផ្តាច់មុខ ដោយផ្តល់នូវជម្រើសដ៏ប្រាកដប្រជា ហើយវានឹងនាំឱ្យមានសេវាកម្មដឹកជញ្ជូនកាន់តែច្រើន ដែលឆ្លើយតបទៅនឹងតម្រូវការឱ្យមានការដឹកជញ្ជូនប្រភេទផ្សេងៗគ្នា។

ខ. **គោលដៅ និង គោលបំណង:** គោលដៅនៃគម្រោងគឺ (១) គាំទ្រការធ្វើសមាហរណកម្មនៃប្រទេសកម្ពុជាចូលទៅក្នុងបណ្តាញផ្លូវរថភ្លើងតំបន់និងអនុតំបន់នៅភាគខាងលិចនៃអនុតំបន់ ដោយផ្តល់ការតភ្ជាប់ផ្លូវរថភ្លើងទៅកាន់ប្រទេសថៃ (២) បង្កើនភាពស័ក្តិសិទ្ធិនៃសេវាកម្មដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជា និង ទៅកាន់ប្រទេសជិតខាងរបស់កម្ពុជា ដោយផ្តល់ជម្រើសផ្លូវនិងវិធីដឹកជញ្ជូនសម្រាប់ពាណិជ្ជកម្មនាំចូលនិងនាំចេញរបស់កម្ពុជា (៣) កាត់បន្ថយចំណាយលើការថែទាំផ្លូវ និង ហានិភ័យចរាចរ ដោយផ្ទេរទំនិញធ្ងន់និងគ្រោះថ្នាក់ទាំងឡាយឱ្យទៅប្រព័ន្ធផ្លូវរថភ្លើងដែលអាចទុកចិត្តបានវិញ (៤) ត្រួសត្រាយផ្លូវសម្រាប់ការធ្វើសមាហរណកម្មអនុតំបន់បន្ថែមទៀតនៅក្នុងពេលអនាគត ដោយសម្រួលដល់ការសម្រេចបាននូវការតភ្ជាប់ផ្លូវរថភ្លើងពីសឹង្ហបុរីដល់គុនមីង និង (៥) បង្កើនតម្លាភាព និង លុបបំបាត់ការខាតបង់ខាងហិរញ្ញវត្ថុបច្ចុប្បន្នលើផ្លូវរថភ្លើង ដោយរៀបចំរចនាសម្ព័ន្ធរថភ្លើងឡើងវិញឱ្យក្លាយទៅជាភាពជាដៃគូរសាធារណៈនិងឯកជន (PPP) និង ដោយបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិប្រកបដោយតម្លាភាពមួយសម្រាប់ផ្លូវរថភ្លើង។

គ. **សមាសភាគ ទិន្នផល សមិទ្ធិផល:** ចាត់ចែងឥណទានក្នុងឆ្នាំ ២០០៥ ដើម្បីសុំការអនុម័តនៅដើមឆ្នាំ ២០០៦ និង បញ្ចប់ការងារសាងសង់មុនដំណាច់ឆ្នាំ ២០១០ ដែលនាំទៅដល់ការស្តារផ្លូវរថភ្លើងឡើងវិញទាំងស្រុង រួមទាំងស្ពាន និង រចនាសម្ព័ន្ធនិងសំណង់ដទៃទៀតនៃផ្លូវរថភ្លើងប្រវែងប្រហែលជា ៥០ គីឡូម៉ែត្រទៅកាន់ព្រំដែនជាមួយប្រទេសថៃ

ដែលត្រូវបានបំផ្លាញក្នុងសម័យសង្គ្រាម។ ប្រការនេះបង្កើតឡើងវិញនូវការតភ្ជាប់ផ្លូវរថភ្លើងរវាងប្រទេសកម្ពុជា និង បណ្ដាញផ្លូវរថភ្លើងនៅ GMS ភាគខាងលិច។ TA ផ្ដល់ប្រឹក្សាស្របគ្នាមួយនឹងត្រូវបានអនុវត្តនៅក្នុងឆ្នាំ ២០០៥-២០០៦ ដើម្បីរៀបចំរចនាសម្ព័ន្ធវិស័យផ្លូវរថភ្លើងឡើងវិញ។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** លទ្ធផលរំពឹងនៃ TA ផ្ដល់ប្រឹក្សា នឹងគឺជាប្រតិបត្តិករផ្លូវរថភ្លើងមួយ ដែលត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញជាមួយនឹងភាពជាម្ចាស់រួមគ្នានៃវិស័យសាធារណៈ និងឯកជន ដែលអាចអភិវឌ្ឍផ្លូវរថភ្លើងបន្ថែមទៀតខាងផ្នែកពាណិជ្ជកម្ម បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីក្លាយទៅជាប្រតិបត្តិករដឹកជញ្ជូនមួយដែលមានលក្ខណៈទំនើបនិងស័ក្តិសិទ្ធិយ៉ាងពេញលេញ។ ដំណើរការនេះ ក៏នឹងផ្ដល់ផងដែរនូវឧទាហរណ៍មួយនៃការអនុវត្តន៍ដ៏មានតម្លាភាពនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញតាមរយៈការបង្កើត PPP ដែលអាចត្រូវបានធ្វើជាគម្រូនៅក្នុងវិស័យដទៃទៀតនៅប្រទេសកម្ពុជា និងនៅក្នុងទូទាំងអនុតំបន់។ លទ្ធផលរំពឹងនៃគម្រោងឥណទាននេះ នឹងគឺជាផ្លូវរថភ្លើងដែលមានប្រវែងប្រហែល ៦០០ គីឡូម៉ែត្រ ដែលត្រូវបានស្ដារឡើងវិញដល់កម្រិតស្ដង់ដារមានសុវត្ថិភាពមួយជាមួយនឹងល្បឿនធ្វើ ដំណើរប្រហែល ៥០ គីឡូម៉ែត្រក្នុងមួយម៉ោង និង ផ្លូវរថភ្លើងបាត់បង់ប្រវែងប្រហែល ៤៨ គីឡូម៉ែត្រដែលត្រូវបានបង្កើតឡើងវិញដល់កម្រិតស្ដង់ដារដូចគ្នា។ ប្រការនេះ នឹងផ្ដល់នូវមូលដ្ឋានសម្រាប់កិច្ចអភិវឌ្ឍន៍នាពេលអនាគតនូវផ្លូវរថភ្លើងទាក់ទិននឹងពាណិជ្ជកម្ម។ លទ្ធផលរំពឹងនៃ TA រៀបចំរចនាសម្ព័ន្ធឡើងវិញនេះនឹងគឺជាការបង្កើតនិយ័តករ ផ្លូវរថភ្លើងដ៏សកម្មមួយដែលអាចត្រួតពិនិត្យ និងជម្រុញយ៉ាងមានប្រសិទ្ធិភាពនូវកិច្ចអភិវឌ្ឍន៍នាពេលអនាគតនៃអនុវិស័យនេះ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ច ឬបរិស្ថាន:** គេឃើញមានការរំលោភយកដីចំណីផ្លូវរថភ្លើងមានស្រាប់ ដែលនឹងតម្រូវឱ្យមានការតាំងទីលំនៅឡើងវិញ។ ទំហំនិងភាពធ្ងន់ធ្ងរនៃបញ្ហានេះនឹងត្រូវបានពិនិត្យឡើងវិញ ជាផ្នែកមួយនៃការរៀបចំគម្រោង ហើយផែនការតាំងទីលំនៅឡើងវិញមួយនឹងត្រូវបានរៀបចំនិងអនុវត្តស្របតាមនោះ ក្រោមក្របខ័ណ្ឌតាំង-ទីលំនៅឡើងវិញដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា និង ADB។ បញ្ហាទាក់ទិននឹងក្រុមភាគតិច យេនឌ័រ និង ភាពក្រីក្រ នឹងត្រូវបានពិនិត្យឡើងវិញជាផ្នែកមួយនៃការពិនិត្យគម្រោង ហើយវិធានការសម្រាលនឹងត្រូវបានអនុវត្តប្រសិនបើចាំបាច់។ ការបារម្ភមួយគឺការកាត់បន្ថយបុគ្គលិកនៅក្នុងរាជាយស្ម័យយានកម្ពុជា (RRC) ជាផ្នែកមួយនៃដំណើរការ PPP ដែលនៅក្នុងនោះ គេអាចចាំបាច់ត្រូវរៀបចំនិងផ្ដល់មូលនិធិដល់កម្មវិធីទូទាត់គោលនយោបាយគ្រប់គ្រាន់។ គម្រោងនេះគឺសម្រាប់ការស្ដារនិងការបង្កើតឡើងវិញនូវផ្លូវរថភ្លើងតាមខ្សែមានស្រាប់ ហើយដោយហេតុ-នេះ ពុំឃើញមានការបារម្ភខាងបរិស្ថានជាធំដុំឡើយ។ លទ្ធភាពកែលំអប្រព័ន្ធលូបង្ហូរទឹកនៅកន្លែងដែលផ្លូវរថភ្លើងឆ្លង-កាត់តំបន់វាលរាបលិចទឹកនៃបឹងទន្លេសាប នឹងត្រូវបានវាយតម្លៃ ជាផ្នែកមួយនៃការរៀបចំគម្រោង។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** អនុសាសន៍និងដំណើរការនៃ PPP នឹងត្រូវបានកត់ត្រាទុកយ៉ាងជិត-

ដល់តាមការកំណត់របស់ PPIAF ដើម្បីអនុញ្ញាតឱ្យមានការតាមឃ្លាំមើល និង ការយកគម្រូតាមដំណើរការនេះនៅទីកន្លែងផ្សេង។ ដំណើការ PPP និង ការវាយតម្លៃបរិស្ថាននិងសង្គម នឹងតម្រូវឱ្យមានការពិគ្រោះយោបល់យ៉ាងច្រើនជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗ ដែលរួមមានស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធនៅប្រទេសកម្ពុជានិងថៃ អ្នកប្រើប្រាស់ផ្លូវរថភ្លើងបច្ចុប្បន្ននិងអនាគត និង អ្នកដែលអាចជាវិនិយោគិនឯកជន បុគ្គលិកនិងថ្នាក់គ្រប់គ្រង RRC ប្រជាជនទូទៅដែលរស់នៅនៅជិតផ្លូវរថភ្លើង និង អាជ្ញាធរមូលដ្ឋាន ដែលទទួលផលប៉ះពាល់ពីគម្រោង ជាពិសេសនៅប៉ោយប៉ែត។

**៧. ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ក្រសួងសាធារណៈការនិងដឹកជញ្ជូន

**៨. ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬ ការចាប់បដិសន្ធិជំនួយ:** ក្នុងអំឡុងពេលបេសកកម្មសិក្សាក្នុងខែ ឧសភា ឆ្នាំ ២០០៣ សំណើនេះត្រូវបានពិភាក្សាជាមួយតំណាងមកពីក្រសួងពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជានិងថៃ ក៏ដូចជាមន្ត្រីអាស៊ានពាក់ព័ន្ធ អំពីការចាប់អារម្មណ៍លើការគាំទ្រសំណើនិងលទ្ធភាពគាំទ្រសំណើ។ អាយស្ម័យយានភូមិន្ទកម្ពុជា (RRC) និង អាយស្ម័យយានរដ្ឋនៃប្រទេសថៃ ត្រូវបានពិគ្រោះយោបល់អំពីវិធីអនុវត្តន៍ និង អ្នកប្រើប្រាស់វិស័យឯកជនបច្ចុប្បន្ននិងអនាគតនៃអាយស្ម័យយាននៅកម្ពុជានិងថៃ អំពីតម្រូវការរបស់ពួកគេចំពោះការកែលំអសេវាកម្ម និង ការស្ម័គ្រចិត្តចូលរួមនិងវិនិយោគលើ PPP។ អនុស្សរណៈនៃការយោគយល់មួយដែលកំណត់គម្រោងត្រូវបានចុះហត្ថលេខាជាមួយក្រសួងសាធារណៈការនិងដឹកជញ្ជូននៅកម្ពុជា។ ក្នុងខែ កញ្ញា ឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានស្នើជាផ្លូវការសុំឱ្យ ADB ផ្តល់ការគាំទ្រចំពោះការរៀបចំរចនាសម្ព័ន្ធនិងការស្តារអយស្ម័យយានឡើងវិញ។

**៩. កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍:**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់: CSP ថ្មី (ឆ្នាំ ២០០២-២០០៤) និង CSP ថ្មី (ឆ្នាំ ២០០៤-២០០៦)។

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទាន: ខែ មករា ឆ្នាំ ២០០៦
មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): ខែ មករា ឆ្នាំ ២០០៥
មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង):

គ. អំឡុងពេលនិងរយៈពេលនៃជំនួយ

កម្ចីឥណទាន : ២០០៦-២០១០ (៥ ឆ្នាំ)
មិនមែនជាកម្ចីឥណទាន : ២០០៥

## ១០. ផែនការហិរញ្ញប្បទាន

ក. សម្រាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: មិនទានសម្រេច ។

☒ ផ្សេងទៀត: ហិរញ្ញប្បទានរួម និង ការគាំទ្រខាងសំភារៈពីប្រទេសអាស៊ាន ។

រាជរដ្ឋាភិបាលប្រទេសថៃនឹងបង្កើតហេដ្ឋារចនាសម្ព័ន្ធចាំបាច់នៅក្នុងប្រទេសថៃ និង នឹងពិចារណាលើការគាំទ្រកាន់តែទូលាយប្រសិនបើមានការគាំទ្រយ៉ាងទូលាយពីអាស៊ាន ។ រដ្ឋាភិបាលប្រទេសម៉ាឡេស៊ីបានផ្តល់ផ្លូវរថភ្លើងសម្រាប់ការសាងសង់ឡើងវិញនូវកំណាត់ផ្លូវដែកចម្ងាយ ៤៨ គីឡូម៉ែត្រទៅកាន់ព្រំដែនប្រទេសថៃ និង អាចផ្តល់ផ្លូវដែកនិងធាតុចូលដទៃបន្ថែមទៀតសម្រាប់ការស្តារឡើងវិញនូវផ្នែកដទៃទៀតនៃផ្លូវរថភ្លើងនេះ ។ ធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ បានសម្តែងការចាប់-អារម្មណ៍លើការផ្តល់ហិញ្ញប្បទានដល់គម្រោងនេះមួយចំណែក ។ ចំនួន នៅមិនទាន់សម្រេចនៅឡើយ ។

| ប្រភព | ចំនួន (លានដុល្លារ) |
|---|---|
| ហិរញ្ញប្បទាន ADB | |
| ហិរញ្ញប្បទានរដ្ឋាភិបាល | |
| ហិរញ្ញប្បទានផ្សេងទៀត | |
| **ចំណាយសរុប** | ៤០,០ |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ខ. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស: ៥00.000 ដុល្លារ

☒ ផ្សេងទៀត:

CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ ។

## តារាង ក៥.១១: កិច្ចអភិវឌ្ឍន៍ទេសចរណ៍ GMS ដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រ

## ឯកសារគោលគំនិត

**កាលបរិច្ឆេទ:** ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

☒ ប្រភេទកម្ចីឥណទាន

☒ ឥណទានគម្រោង

☐ ឥណទានកម្មវិធីកំណែទម្រង់

☐ ឥណទានវិស័យ

☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ

☐ ផ្សេងទៀត:

☒ ប្រភេទមិនមែនជាកម្ចីឥណទាន

☒ សំរាប់ត្រៀមរៀបចំគម្រោង

☐ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង

☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ

☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន

☐ ផ្សេងទៀត:

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ឧស្សាហកម្មនិងពាណិជ្ជកម្ម

អនុវិស័យ: ទេសចរណ៍

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

☐ អន្តរាគមន៍មានមុខព្រួញ

☒ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

ប្រធានបទ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ ចីរភាពបរិស្ថាន

☐ កិច្ចអភិវឌ្ឍន៍សង្គមរួម ☒ កិច្ចសហប្រតិបត្តិការតំបន់

☐ អភិបាលកិច្ច ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន

☒ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍

**៣. វិសាលភាពគ្របដណ្តប់**

☐ ប្រទេស ☒ អនុតំបន់ ☐ អន្តរតំបន់

☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

**៤. ផ្នែក/នាយកដ្ឋានទទួលបន្ទុក:** ផ្នែកវិស័យសង្គមកិច្ច/នាយកដ្ឋានមេគង្គ

**៥. មន្ត្រី ADB ទទួលបន្ទុក:** A. Perdiguero អ្នកសេដ្ឋកិច្ចគម្រោង

**៦. ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំតំបន់:** ទេសចរណ៍ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសំខាន់ទី ១១ ក្រោមក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធី GMS រយៈពេល ១០ ឆ្នាំ ដែលបានអនុម័តដោយអ្នកដឹកនាំប្រទេស GMS នៅក្នុងឆ្នាំ ២០០២។ អ្នកដឹកនាំប្រទេស GMS បានទទួលស្គាល់ថា វិធីសាស្ត្រអនុតំបន់មួយសំរាប់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ គឺចាំបាច់ត្រូវតែជំរុញអនុតំបន់នេះអោយទៅជាគោលដៅទេសចរតែមួយ។ ដូច្នេះហើយ ត្រូវតែពង្រីកវិស័យនេះ នឹងបង្កើនអោយមានភាពទាក់ទាញ និង អាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

ខ. **គោលដៅ និង គោលបំណង:** គោលបំណងនៃគម្រោងគឺបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍នៅក្នុង GMS ដើម្បីលើកស្ទួយកិច្ចអភិវឌ្ឍន៍និងធ្វើអោយមានចីរភាពនៃវិស័យទេសចរណ៍និងបរិមាណ និងការចែកចាយអត្ថប្រយោជន៍សេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ។

គ. **សមាសភាគ និង សមិទ្ធិផល:** គម្រោងនឹងដាក់បញ្ចូលសមាសភាគដូចតទៅនេះ (១) ផែនការរកទីផ្សារ និងផ្សព្វផ្សាយទីផ្សាររបស់ GMS មួយ និងផែនការមួយដែលលើកនឹងលើកស្ទួយអនុតំបន់នេះ អោយទៅជាគោលដៅទេសចរតែមួយគត់ (២) ហេដ្ឋារចនាសម្ព័ន្ធ ដែលបំរើអោយវិស័យទេសចរណ៍របស់ GMS (៣) កិច្ចអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យទេសចរណ៍ GMS ដោយយកចិត្តទុកដាក់ជាក់លាក់លើតម្រូវការខាងយេនឌ័រ (៤) ការគ្រប់គ្រងប្រកបដោយចីរភាពនូវតំបន់បេតិកភណ្ឌវប្បធម៌និងធម្មជាតិសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ (៥) វិស័យទេសចរណ៍ដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រក្នុងសហគមន៍ក្នុងលក្ខណៈ សមាហរណកម្មយេនឌ័រ (៦) ការសម្រួលដល់ការធ្វើដំណើររបស់ទេសចរទៅកាន់ប្រទេស GMS និងការធ្វើដំណើរនៅក្នុង GMS និង (៧) ការ គាំទ្រចំពោះ AMTA និង ក្រុមការងារវិស័យទេសចរណ៍ GMS។

ឃ. **លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:** (១) សកម្មភាពរកទីផ្សារទេសចរណ៍ GMS ត្រូវបានអនុវត្ត (២) គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលបំរើអោយវិស័យទេសចរណ៍ត្រូវបានអភិវឌ្ឍ (៣) ធនធានមនុស្សសម្រាប់វិស័យទេសចរណ៍ GMS ត្រូវបានអភិវឌ្ឍ (៤) ភាពជាដៃគូរវាងឯកជន-សាធារណៈ និងកិច្ចសហប្រតិបត្តិការត្រូវបានបង្កើតឡើងនៅក្នុង GMS (៥) ការគ្រប់គ្រងប្រកបដោយចិរភាពនូវបេតិកភ័ណ្ឌវប្បធម៌និងធម្មជាតិ ជាពិសេសតំបន់ទេសចរ ត្រូវបានកែលំអ (៦) ការធ្វើដំណើររបស់ទេសចរនៅក្នុង GMS និងទៅកាន់ប្រទេស GMS ត្រូវបានជួយសម្រួល។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថាន:** កំណើននៃការធ្វើចលនារបស់ទេសចរនៅក្នុង GMS ប្រសិនបើមិនត្រូវបានគ្រប់គ្រងត្រឹមត្រូវ នឹងអាចមានផលប៉ះពាល់អវិជ្ជមានលើមេរោគអេដស៍/ជម្ងឺអេដស៍ និង ការជួញដូរស្ត្រីនិងកុមារ។ ការកែលំអរហេដ្ឋារចនាសម្ព័ន្ធ ប្រសិនបើមិនត្រូវបានគ្រប់គ្រងឱ្យបានសមស្របទេ ក៏អាចធ្វើឱ្យប្រជាជនធ្វើបំលាស់ទីច្រើន និងបង្កើតផងដែរនូវការអន្តរាយដល់បរិស្ថាន។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផល:** ការផ្សព្វផ្សាយនូវលទ្ធផលដែលអនុវត្តន៏បានតាមរយៈរបាយការណ៏ និង ឯកសារសង្ខេប សិក្ខាសាលា និង សន្និសីទសារព័តិមាន។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើង:** ស្ថាប័នប្រតិបត្តិ គឺត្រូវតែជាអង្គភាពទេសចរជាតិដែលនៅក្នុងប្រទេសនិមួយៗ។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/ការចូលរួម និង ការផ្តល់មតិរបស់អ្នកទទួលផលប្រយោជន៏អំពីជំនួយ:** រដ្ឋាភិបាលនៃប្រទេស GMS វិស័យឯកជននៅក្នុងប្រទេស GMS ផ្សេងៗ NGOs និង សហគមន៏មូលដ្ឋាន នឹងចូលរួមនៅក្នុងការកំណត់និងការអនុវត្តន៏អនុគម្រោង ដែលនឹងជួយណែនាំអោយលើកឡើងជាសមាសភាគផ្សេងក្នុងគំរោង TA និងបង្ហាញពីទីតាំងភូមិសាស្ត្រដែលគំរោង TA ត្រូវអនុវត្តន៏។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៏:**

ក. ត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំតំបន់ GMS សម្រាប់ឆ្នាំ ២០០៦ (បម្រុងនៅក្នុង CSPU)

ខ. កាលបរិច្ឆេទនិងរយៈពេលនៃជំនួយ

មិនមែនជាកម្ចីឥណទាន: ខែ មករា ឆ្នាំ ២០០៥ ដល់ ខែ ធ្នូ ឆ្នាំ ២០០៩

១០. **ផែនការហិរញ្ញប្បទាន**

ក. សំរាប់ការផ្តល់កម្ចីឥណទាន

☐ ធនធានទុនធម្មតា:

☒ មូលនិធិអភិវឌ្ឍន៍អាស៊ី: ចំនួនសរុប ៤០ លានដុល្លារ ដែលនៅក្នុងនោះ ១០ លានដុល្លារគឺសម្រាប់កម្ពុជា។

☐ ផ្សេងទៀត:

ប្រសិនបើចាំបាច់ ត្រូវមានការចូលរួមហិរញ្ញប្បទានពីប្រភពផ្សេងៗ ចូរបង្ហាញចំនួន និងប្រភព: ១៦០.០០ ដុល្លារ (ប្រភពនឹងត្រូវបញ្ជាក់តាមក្រោយ)។ បើដឹង សូមដាក់តំលៃប៉ាន់ស្មាន និងទំនាក់ទំនងហិរញ្ញប្បទាន។

| **ប្រភព** | **ចំនួន (លានដុល្លារ)** |
|---|---|
| ហិរញ្ញប្បទាន ADB | ១០,០ |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ៥,០ |
| ហិរញ្ញប្បទានផ្សេងទៀត | ០,០ |
| **ចំណាយសរុប** | **១៥,០** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB។

ខ. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

☐ មិនចាំបាច់មានធនធាន ក្រៅតែពីបុគ្គលិក ADB

☐ ថវិការដ្ឋបាលរបស់ ADB:

☒ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស: ៩០០.០០០ ដុល្លារ

☐ ផ្សេងទៀត: ហិរញ្ញប្បទានរួម ១៦០.០០០ ដុល្លារ

ប្រសិនបើចាំបាច់ ត្រូវមានការចូលរួមហិរញ្ញប្បទានពីប្រភពផ្សេងៗ ចូរបង្ហាញចំនួន និងប្រភព: ១៦០.០០ ដុល្លារ (ប្រភពនឹងត្រូវបញ្ជាក់តាមក្រោយ)។ បើដឹង សូមដាក់តំលៃប៉ាន់ស្មាន និងទំនាក់ទំនងហិរញ្ញប្បទាន។

| **ប្រភព** | **ចំនួន (ពាន់ដុល្លារ)** |
|---|---|
| ហិរញ្ញប្បទាន ADB | ៩០០ |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ០ |
| ហិរញ្ញប្បទានផ្សេងទៀត | ១៦០ |
| **ចំណាយសរុប** | **១.០៦០** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB។

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស។

## តារាង ក៥.១២: គំនិតផ្តួចផ្តើមអាជីវកម្មនៅក្នុងកិច្ចអភិវឌ្ឍន៍ជនបទកម្ពុជា (C-BIRD)

## ឯកសារគោលគំនិត

កាលបរិច្ឆេទ: ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**១. ប្រភេទ/ទម្រង់នៃជំនួយ**

☐ ប្រភេទកម្ចីឥណទាន

☐ ឥណទានគម្រោង

☐ ឥណទានកម្មវិធីកំណែទម្រង់

☐ ឥណទានវិស័យ

☐ ឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យ

☐ ផ្សេងទៀត:

☒ ប្រភេទមិនមែនជាកម្ចីឥណទាន

☐ សំរាប់ត្រៀមរៀបចំគម្រោង

☒ ក្រៅពីសំរាប់ត្រៀមរៀបចំគម្រោង

☐ ការងារផ្នែកសេដ្ឋកិច្ច ប្រធានបទ និង វិស័យ

☐ កិច្ចអភិវឌ្ឍន៍ស្ថាប័ន

☒ ផ្សេងទៀត: ការវិភាគស្ថានភាព កិច្ចអភិវឌ្ឍន៍យុទ្ធសាស្ត្រ និង ការកសាងសមត្ថភាព

**២. មុខព្រួញជំនួយ**

ក. ប្រសិនបើជំនួយផ្តោតលើវិស័យឬអនុវិស័យជាក់លាក់មួយ ចូរកំណត់

វិស័យ: ជនបទ

អនុវិស័យ: កសិកម្មក្រៅកសិដ្ឋាន និង អាជីវកម្មតូចតាច

ខ. សម្រាប់ការត្រៀមរៀបចំគម្រោងនិងការផ្តល់ឥណទាន ចំណាត់ថ្នាក់

☒ អន្តរាគមន៍មានមុខព្រួញ

☐ អន្តរាគមន៍ទូទៅ

គ. វិស័យប្រធានបទសំខាន់ៗ

☒ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ☐ អភិបាលកិច្ច
☒ កិច្ចអភិវឌ្ឍន៍សង្គមរួម ☐ កិច្ចសហប្រតិបត្តិការតំបន់
☐ យេនឌ័រនិងកិច្ចអភិវឌ្ឍន៍ ☐ កិច្ចអភិវឌ្ឍន៍វិស័យឯកជន
☐ ចីរភាពបរិស្ថាន ☒ កិច្ចអភិវឌ្ឍន៍សមត្ថភាព
☐ ផ្សេងទៀតៈ

៣. វិសាលភាពគ្របដណ្តប់

☒ ប្រទេស ☐ អនុតំបន់ ☐ អន្តរតំបន់
☐ កិច្ចអភិវឌ្ឍន៍គោលនយោបាយថ្នាក់ជាតិ

៤. **ផ្នែក/នាយកដ្ឋានទទួលបន្ទុកៈ** បេសកកម្មប្រចាំប្រទេសកម្ពុជា ផ្នែកកសិកម្ម បរិស្ថាននិងធនធានធម្មជាតិ/នាយកដ្ឋានមេគង្គ

៥. **មន្ត្រី ADB ទទួលបន្ទុកៈ** S. Mar មន្ត្រីវិស័យសង្គម/ភាពក្រីក្រ M. de Alwis អ្នកឯកទេសហិរញ្ញវត្ថុជាន់ខ្ពស់

៦. **ពិពណ៌នាអំពីជំនួយ**

ក. **សារៈតា/ការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រប្រចាំប្រទេស/តំបន់ៈ** ការជម្រុញកិច្ចអភិវឌ្ឍន៍វិស័យឯកជន និង មុខរបរនៅតំបន់ជនបទ គឺជាសរសរទ្រូងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាល បានទទួលស្គាល់តួនាទីរបស់ខ្លួនក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមរបស់សាជីវកម្មនៅក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្រ និងដោយបង្កើតបរិស្ថានអំណោយផលសម្រាប់សេដ្ឋកិច្ចផ្អែកលើជនបទ ដែលនឹងគាំទ្រដល់កំណើនវិស័យឯកជន ដែលនឹងបង្កើតកាលានុវត្តភាពការងារបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅជនបទ។

យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស (CSP) របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺមានទំនាក់ទំនងយ៉ាងពេញលេញជាមួយនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ភាពជាប់គាំងសេដ្ឋកិច្ចនៅជនបទ គឺជាមូលហេតុចំបងមួយនៃគម្លាតដ៏ធំធេងរវាងជនបទនិងទីក្រុងនៅកម្ពុជា ហើយនិងបង្កើតអន្ទាក់មួយនៅក្នុងចំណោមប្រជាជនជនបទ និងដោយហេតុនេះ ធ្វើឱ្យមានហានិភ័យដល់កិច្ចប្រឹងប្រែងរបស់ប្រទេសក្នុងការកាត់បន្ថយភាពក្រីក្រ។

គម្រោងនេះ ត្រូវបានគេរៀបចំឡើងដើម្បីអនុវត្តនៅប្រទេសកម្ពុជា តាមគំរូបទពិសោធន៍ប្រកបដោយជោគជ័យមួយនៅក្នុងប្រទេសថៃដែលគេហៅថា T-BIRD ឬ គំនិតផ្តួចផ្តើមអាជីវកម្មសម្រាប់កិច្ចអភិវឌ្ឍន៍ជនបទប្រទេសថៃ។ សាជីវកម្ម (ក្រុមហ៊ុនតូចនិងធំ) អាចផ្ទេរជំនាញអាជីវកម្មដល់គ្រួសារក្រីក្រ (ផលិតកម្ម ការរកទីផ្សារ ការគ្រប់គ្រងហិរញ្ញវត្ថុ) ជួយដោះស្រាយបញ្ហាទាំងឡាយដែលអ្នកភូមិក្រីក្រជួបប្រទះ និង ជួយអភិវឌ្ឍន៍ពួកគេឱ្យខ្លួនទីពឹងខ្លួនបាន។

ក្រោមគម្រោង T-BIRD អង្គការអាជីវកម្មដែលចូលរួមផ្តល់ការបណ្តុះបណ្តាល និងណែនាំអ្នកភូមិអំពីការប្រកបអាជីវ-កម្មប្រកបដោយចិរភាព។ ពួកគេដើរតួនាទីជាអ្នកផ្តល់បទពិសោធន៍ រហូតដល់ពេលដែលអ្នកភូមិអាចគ្រប់គ្រងអាជីវកម្មរបស់ខ្លួនបាន។ ដោយធ្វើដូច្នេះ វិស័យអាជីវកម្មបង្ហាញការទទួលខុសត្រូវខាងសង្គមរបស់ខ្លួន ដែលលើកស្ទួយសេចក្តីគោរពរបស់ពួកគេនៅក្នុងក្រសែភ្នែកសាធារណៈ។ ពួកគេក៏បានចំណេញជាហិរញ្ញវត្ថុផងដែរ ពីការផ្តល់សេវាកម្មពីខាងក្រៅប្រតិបត្តិការខ្លះៗរបស់ពួកគេ។

ឯកសារគោលគំនិតស្តីពី C-BIRD មានប្រភពដើមពីទស្សនៈកិច្ចមួយរបស់ប្រធាន ADB ទៅកាន់ប្រទេសថៃនៅដើមឆ្នាំ ២០០៤។ នៅក្នុងដំណើរទស្សនៈកិច្ចមួយរបស់គាត់ ដើម្បីសង្កេតមើលបណ្តុំសកម្មភាពនៃសមាគមអភិវឌ្ឍន៍ប្រជាជន និងសហគមន៍ (PDA) នៃប្រទេសថៃ លោកប្រធានត្រូវបានគេបង្ហាញជូនពីគម្រោង T-BIRD។ ដោយចាប់អារម្មណ៍លើសមិទ្ធិផលនៃ T-BIRD និង ភាពជាដៃគូរប្រកបដោយជោគជ័យដែលត្រូវបានធ្វើឡើងរវាងរដ្ឋាភិបាលនិងវិស័យឯកជន លោកប្រធានបានស្នើសុំឱ្យ MKRD ពិនិត្យមើលលទ្ធភាពអនុវត្តគម្រោងដូចគ្នាមួយនៅកម្ពុជា។ ក្នុងន័យនេះ MKRD បានរៀបចំឱ្យមានទំនាក់ទំនងរវាង PDA និង មន្ត្រីកម្ពុជា ដែលនាំឱ្យមានបុគ្គលិក CARM ចូលរួមក្នុងសិក្ខាសាលា NGO និងវិស័យឯកជន ដែលត្រូវបានរៀបចំឡើងដោយ PDA និង ការទស្សនាបណ្តុំសកម្មភាពរបស់ T-BIRD។ ក្នុងខែ កញ្ញា ឆ្នាំ ២០០៤ សិក្ខាសាលាមួយត្រូវបានរៀបចំឡើងដោយ CARM ផ្តល់ហិរញ្ញប្បទានពីមូលនិធិក្រោម TA លេខ 6110 (ជម្រុញភាពជាដៃគូរ និង បង្កើនល្បឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រនៅក្នុង GMS)។

អាស្រ័យលើការអនុវត្តន៍ប្រកបដោយជោគជ័យនៃគម្រោងនេះ គេមានផែនការបន្តជាមួយនឹងជំនួយបន្ថែមទៀត ប្រសិនបើចាំបាច់ ដែលវិស័យឯកជនឬរដ្ឋាភិបាលមិនអាចផ្តល់បាន។ គោលបំណងគឺដើម្បីកសាងគ្រឹះដ៏រឹងមាំមួយនៃទស្សនាទាន C-BIRD ដើម្បីធានាឱ្យបាននូវជោគជ័យនៃគម្រោងនេះ។

ខ. **គោលដៅ និង គោលបំណង:** វាយតម្លៃលទ្ធភាពយកគម្រូតាមវិធីសាស្ត្ររបស់ T-BIRD នៅក្នុងប្រទេសកម្ពុជា និងកសាងយន្តការសម្របសម្រួលប្រសិនបើចាំបាច់ ដែលនឹងជម្រុញឱ្យមានវិធីសាស្ត្រនៃការចូលរួមនិងប្រកបដោយចិរភាពចំពោះការកាត់បន្ថយភាពក្រីក្រ និង កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដែលរួមមានសាជីវកម្ម ស្ថាប័នរដ្ឋាភិបាល NGO និងអ្នកភូមិក្រីក្រ។

គ. **សមាសភាគ និង សមិទ្ធិផល :**

(i) **ការវិភាគស្ថានភាព:** សមាសភាគនេះនឹង (ក) វាយតម្លៃការចូលរួមនាពេលបច្ចុប្បន្នរបស់សាជីវកម្មនៅក្នុងសកម្មភាពអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចនៅតាមតំបន់ជនបទ (ខ) វាយតម្លៃគម្រូបច្ចុប្បន្ននិងគម្រូដែលអាចធ្វើទៅ

បាននៃភាពជាដៃគូររវាងផ្នែកឯកជន សាធារណៈ និង បណ្ដាភូមិដែលចូលរួម នៅក្នុងសកម្មភាពអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចនៅតាមតំបន់ជនបទ (គ) បង្កើតជម្រើសប្រកបដោយចីរភាពនៅក្នុងការសម្រួលឱ្យសាជីវកម្មបានចូលរួមចំណែកដល់សកម្មភាពអភិវឌ្ឍន៍ជនបទនិងសង្គម និង (ឃ) កំណត់និងវាយតម្លៃបណ្ដាភូមិដែលមានសក្ដានុពល។ ការសិក្សានិងរួមមានការពិនិត្យមើលឡើងវិញដ៏ច្រើននូវឯកសារមានស្រាប់ អង្កេតគម្រូ និង ការពិភាក្សាក្រុមគោលដៅជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ។

(ii) **បង្កើតឡើងភាពជាដៃគូរ:** សមាសភាគនេះនឹង (ក) បង្កើតក្រុមការងារ C-BIRD មួយ (តាមរយៈការពិគ្រោះយោបល់ជាមួយភាគីចាប់អារម្មណ៍ទាំងឡាយនៅកម្ពុជា និង ជំនួយបច្ចេកទេសពីបុគ្គលិកនៃសមាគមអភិវឌ្ឍន៍ប្រជាជននិងសហគមន៍ (PDA) នៅប្រទេសថៃ ដែលនឹងសម្របសម្រួលការអនុវត្តន៍គម្រោងនេះ) (ខ) ផ្ដល់ការគាំទ្រនៅក្នុងការរៀបចំកិច្ចប្រជុំទីមួយនៃក្រុមការងារ C-BIRD និង ទ្រទ្រង់ប្រតិបត្តិការក្រុមការងារនេះរហូតដល់ពេលបង្កើតបាននូវស្ថាប័ន C-BIRD និង (គ) ផ្ដល់ការគាំទ្របច្ចេកទេសដើម្បីជួយក្រុមការងារក្នុងការបង្កើតភាពជាដៃគូរប្រកបដោយចីរភាពជាមួយវិស័យឯកជន និង NGO។ ក្រុមការងារ C-BIRD នឹងរួមមានក្រុមសាជីវកម្មដែលចាប់អារម្មណ៍ NGO និង ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល។ ក្រុមការងារនេះនឹងដើរតួនាទីជាយន្តការមួយដើម្បីចាប់ផ្ដើមគំនិតផ្ដួចផ្ដើមនេះ ដោយមានការជ្រោមជ្រែងពីក្រសួងអភិវឌ្ឍន៍ ជនបទ (MRD) និង ADB។ ដំណើរទស្សនៈកិច្ចទៅកាន់ PAD នៅប្រទេសថៃក៏ត្រូវបានគ្រោងផងដែរ ដើម្បីសិក្សាអំពីគំនិតផ្ដួចផ្ដើមប្រកបដោយជោគជ័យនៅទីនោះ ដែលរួមមាន NGO ស្ថាប័នរដ្ឋាភិបាល និង វិស័យឯកជនរួមទាំងសហគ្រិនភូមិផងដែរ។

(iii) **យុទ្ធសាស្ត្រទូលំទូលាយ:** សមាសភាគនេះព្យាយាមបង្កើតស្ថាប័ន C-BIRD និង អភិវឌ្ឍយុទ្ធសាស្ត្ររួមមួយ ដើម្បីយកគម្រូតាមវិធីសាស្ត្ររបស់ T-BIRD ផ្អែកលើមូលដ្ឋាននៃធនធានដែលបានទទួលពីសមាសភាគទី ១ និង ទី ២។

**ឃ. លទ្ធផលរំពឹងទុក និង អាចសម្រេចបាន:**

(i) វិភាគស្ថានភាពនៃការចូលរួមរបស់ក្រុមសាជីវកម្មនៅក្នុងសកម្មភាពអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច នៅតាមតំបន់ជនបទកម្ពុជា ដោយកំណត់ប្រភេទ និងគម្រូដែលអាចអនុវត្តបាននៃកិច្ចសហការរវាងអ្នកផ្ដល់ជំនួយស្ថាប័នរដ្ឋាភិបាល NGO និង សហគមន៍ និងសមត្ថភាពរបស់ពួកគេ។

(ii) បង្កើតនិងពង្រឹងក្រុមការងារ C-BIRD មួយដែលនឹងទទួលបន្ទុកលើការកំណត់និងការសម្រួលភាពជាដៃគូររវាងឯកជន និងសាធារណៈដើម្បីគោលបំណងកែលំអជីវិតរបស់ប្រជាពលរដ្ឋក្រីក្រ និងធ្វើការងារឆ្ពោះទៅកាន់ការបង្កើតវិធីសាស្ត្រមួយ ចំពោះការទាក់ទាញជំនួយពីសាជីវកម្មវិស័យ ជាមួយនឹងមូលនិធិអ្នកផ្ដល់

ជំនួយដើម្បីសម្រេចបាននូវវឌ្ឍនភាពសង្គម និង

(iii) យុទ្ធសាស្ត្រទូលំទូលាយមួយដើម្បីយកគម្រូតាមយុទ្ធសាស្ត្រ T-BIRD ដែលអាចត្រូវបានអនុម័តដោយបណ្តាភាគីពាក់ព័ន្ធ នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និង កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចនៅតាមតំបន់ជនបទ។

ង. **បញ្ហាឬការបារម្ភខាងសង្គមកិច្ចឬបរិស្ថានៈ** រដ្ឋាភិបាលមិនអាចដោះស្រាយបញ្ហានៃភាពក្រីក្រនិងភាពគ្មានការងារធ្វើ ដែលកាន់តែកើនឡើងនៅក្នុងប្រទេសតែឯកឯងនោះឡើយ។ ការធ្វើឱ្យសហគមន៍សាជីវកម្មចូលរួមនៅក្នុងកិច្ចអភិវឌ្ឍន៍ នឹង សម្រាលបន្ទុករដ្ឋាភិបាល និង ផ្តល់នូវយុទ្ធសាស្ត្រប្រកបដោយចីរភាពដើម្បីកាត់បន្ថយភាពក្រីក្រ ដោយផ្សារភ្ជាប់សាជីវកម្មជាមួយនឹងបណ្តាសហគមន៍ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេរៀងៗខ្លួន (ដើម្បីកម្លាំងពលកម្ម និងការងារ) ជួយប្រជាពលរដ្ឋក្រីក្រឱ្យចេះជួយខ្លួនឯងដោយបង្កើតកាលានុវត្តភាពសម្រាប់កំណើន និង លទ្ធភាពផ្តល់សេវាកម្ម និងធ្វើឱ្យជីវិតមានលក្ខណៈល្អប្រសើរសម្រាប់មនុស្សគ្រប់រូបដោយធានាបាននូវសុខុដុមសង្គម។

ច. **ផែនការសម្រាប់ផ្សព្វផ្សាយលទ្ធផល/សមិទ្ធិផលៈ** សេចក្តីព្រាងរបាយការណ៍វិភាគនេះ នឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយនៅក្នុងចំណោមភាគីពាក់ព័ន្ធ។ ការពិគ្រោះយោបល់ទាំងឡាយនឹងត្រូវបានធ្វើឡើងនៅក្នុងទូទាំងដំណើរការនៃការអនុវត្តន៍គម្រោងដើម្បីពិភាក្សាបញ្ហាជាក់លាក់ទាំងឡាយ និងដើម្បីប្រមូលយោបល់ត្រឡប់ ជាពិសេស ពីក្រុមសាជីវកម្ម NGO សហគ្រិនភូមិ និង ដៃគូរអភិវឌ្ឍន៍ដទៃទៀត។

៧. **ស្ថាប័នប្រតិបត្តិ/អនុវត្តដែលត្រូវបានស្នើឡើងៈ** ក្រសួងអភិវឌ្ឍន៍ជនបទ (MRD)។ PDA នឹងត្រូវបានជ្រើសរើស (ជាអ្នកពិគ្រោះការងារ) ដើម្បីជួយ MRD អនុវត្តគម្រោង។

៨. **ប្រភេទ/កម្រិតនៃការចូលរួមរបស់រដ្ឋាភិបាល/អ្នកទទួលផលប្រយោជន៍នៅក្នុងការកំណត់ ឬ ការចាប់បដិសន្ធិជំនួយៈ** សិក្ខាសាលាមួយស្តីពីគំនិតផ្តួចផ្តើមអាជីវកម្មគ្រួសារ និង កិច្ចអភិវឌ្ឍន៍ជនបទ ត្រូវបានធ្វើឡើងនៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២00៤ ដែលមានអ្នកចូលរួមជាង ៤0 នាក់ មកពី NGOs ស្ថាប័នអាជីវកម្ម និង ស្ថាប័នរដ្ឋាភិបាល។

៩. **កាលវិភាគសម្រាប់ការរៀបចំគម្រោងជំនួយ ការពិនិត្យ និង ការអនុវត្តន៍ៈ**

ក. ឆ្នាំដែលត្រូវបានដាក់បញ្ចូលក្នុង CSP, CSP ថ្មី, RCSP, RCSP ថ្មី ឬ ផែនការការងារអន្តរតំបន់ៈ ឆ្នាំ ២00៥

ខ. កាលបរិច្ឆេទរំពឹងនៃការដាក់សំណើសុំការឯកភាព

កម្ចីឥណទានៈ

| |
|---|
| មិនមែនជាកម្ចីឥណទាន (ការត្រៀមរៀបចំគម្រោង): <br> មិនមែនជាកម្ចីឥណទាន (ក្រៅពីការត្រៀមរៀបចំគម្រោង): ខែ កក្កដា ឆ្នាំ ២០០៥ |

**១០. ផែនការហិរញ្ញប្បទាន**

ក. សម្រាប់ការមិនផ្តល់កម្ចីឥណទាន

- ☐ មិនចាំបាច់មានធនធានទេ ក្រៅតែពីបុគ្គលិក ADB
- ☐ ថវិការដ្ឋបាលរបស់ ADB:
- ☐ មូលនិធិជំនួយគ្មានសំណងបច្ចេកទេស
- ☒ ផ្សេងទៀត: PRF

| ប្រភព | ចំនួន (ដុល្លារ) |
|---|---|
| ហិរញ្ញប្បទាន ADB | |
| ហិរញ្ញប្បទានរដ្ឋាភិបាល | ១៥.000 (ជាសំភារៈ ឬ សេវាកម្ម) |
| ហិរញ្ញប្បទានផ្សេងទៀត | ១៥0.000 |
| **ចំណាយសរុប** | **១៦៥.000** |

ប្រភព: ការប៉ាន់ស្មានរបស់ ADB ។

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស RCSP = យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ TA = ជំនួយបច្ចេកទេស ។